ADB

# យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស

ខែវិច្ឆិកា ឆ្នាំ២០១៤

## ប្រទេសកម្ពុជា
## ២០១៤-២០១៨

ការចែកចាយឯកសារនេះ ត្រូវបានរិតបន្តឹងរហូតដល់ពេលដែលឯកសារនេះ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ ក្រោយពេលទទួលបានការអនុម័តពីក្រុមប្រឹក្សាភិបាល ធនាគារអភិវឌ្ឍន៍អាស៊ី នឹងផ្សព្វផ្សាយឯកសារនេះជាសាធារណៈ ស្របតាមគោលនយោបាយស្តីពីការទំនាក់ទំនងសាធារណៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១១។

## ធនាគារអភិវឌ្ឍន៍អាស៊ី

## សមមូលនៃរូបិយប័ណ្ណ

(គិតត្រឹមថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៤)

| | | |
|---|---|---|
| ឯកតារូបិយប័ណ្ណ | – | រៀល (KR) |
| KR 1.00 | = | $0.0002 |
| $1.00 | = | KR4,080 |

## អក្សរកាត់

| | | |
|---|---|---|
| ADB | – | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CPS | – | យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស |
| D&D | – | វិមជ្ឈការ និងវិសហមជ្ឈការ |
| GMS | – | មហាអនុតំបន់ទន្លេមេគង្គ |
| M&E | – | ការត្រួតពិនិត្យ និងវាយតម្លៃ |
| NSDP | – | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PFM | – | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PPP | – | ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន |
| PSM | – | ការគ្រប់គ្រងវិស័យសាធារណៈ |
| RCI | – | កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់ |
| RSIII | – | យុទ្ធសាស្ត្រចតុកោណស្តីពី កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី៣ |
| SMEs | – | សហគ្រាសខ្នាតតូច និងមធ្យម |
| TA | – | ជំនួយបច្ចេកទេស |

## សម្គាល់

នៅក្នុងរបាយការណ៍នេះ "$" សំដៅចំពោះដុល្លារសហរដ្ឋអាមេរិក

"ឯកសារនេះ ត្រូវបានបកប្រែចេញពីភាសាអង់គ្លេស ដើម្បីផ្សព្វផ្សាយដល់សាធារណៈជនឱ្យបានកាន់តែទូលំ ទូលាយ។ ភាសាអង់គ្លេស គឺជាភាសាការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ហើយឯកសារច្បាប់ដើមជាភាសាអង់គ្លេសនៃឯកសារនេះ គឺជាឯកសារដែលត្រឹមត្រូវ និង ផ្លូវការតែមួយគត់ របស់ធនាគារអភិវឌ្ឍន៍អាស៊ី។ រាល់ការដកស្រង់ទាំងឡាយណាចេញពីឯកសារនេះ ត្រូវតែយោងទៅលើឯកសារច្បាប់ដើមនៅក្នុងភាសាអង់គ្លេស"។

| | |
|---|---|
| អនុប្រធាន | S. Groff, ប្រតិបត្តិការ ២ |
| អគ្គនាយក | J. Nugent, នាយកដ្ឋានអាស៊ីអាគ្នេយ៍ (SERD) |
| នាយក | E. Sidgwick, និវាសដ្ឋានបេសកកម្មប្រចាំកម្ពុជា (CARM), SERD |
| ប្រធានក្រុម | J. Hansen, សេដ្ឋកិច្ចវិទូជាន់ខ្ពស់ប្រចាំប្រទេស (CARM), SERD |
| | P. Brimble, អ្នកឯកទេសជាន់ខ្ពស់ប្រចាំប្រទេស និវាសដ្ឋានបេសកកម្មប្រចាំភូមា SERD |
| សមាជិកក្រុម | S. Aman-Wooster, អ្នកឯកទេសជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សង្គម (ការពារសុវត្ថិភាព) SERD |
| | S. Ancha, អ្នកឯកទេសជាន់ខ្ពស់ផ្នែកប្រែប្រួលអាកាសធាតុ SERD |
| | H. Aoki, អ្នកឯកទេសជាន់ខ្ពស់វិស័យហិរញ្ញវត្ថុ SERD |
| | E. Araneta, អ្នកឯកទេសជាន់ខ្ពស់ផ្នែកសម្របសម្រួលប្រតិបត្តិការ នាយកដ្ឋានប្រតិបត្តិការវិស័យឯកជន |
| | S. Bando, អ្នកឯកទេសជាន់ខ្ពស់ផ្នែកកិច្ចសហប្រតិបត្តិការតំបន់ SERD |
| | R. Barba, អ្នកឯកទេសជាន់ខ្ពស់ផ្នែកកិច្ចការពារសុវត្ថិភាព (CARM), SERD |
| | G. Bui, សេដ្ឋកិច្ចវិទូផ្នែកធនធានធម្មជាតិ និងកសិកម្ម SERD |
| | C. Chea, អ្នកឯកទេសផ្នែកយេនឌ័រ (CARM), SERD |
| | S. Chea, មន្ត្រីវិភាគគម្រោង (CARM), SERD |
| | T. Dang, អ្នកឯកទេសផ្នែកបរិស្ថាន SERD |
| | S. Date, អ្នកឯកទេសជាន់ខ្ពស់ផ្នែកដឹកជញ្ជូន SERD |
| | L. Ding, អ្នកឯកទេសជាន់ខ្ពស់ផ្នែកពាណិជ្ជកម្ម SERD |
| | P. Doung, មន្ត្រីជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច (CARM), SERD |
| | S. Hel, ជំនួយការគម្រោងជាន់ខ្ពស់ (CARM), SERD |
| | C. Hem, មន្ត្រីគម្រោងជាន់ខ្ពស់ (CARM), SERD |
| | U. Hoque, អ្នកឯកទេសជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សង្គម SERD |
| | N. Ikemoto, អ្នកឯកទេសជាន់ខ្ពស់ផ្នែកបរិស្ថាន SERD |
| | E. Izawa, អ្នកឯកទេសជាន់ខ្ពស់ផ្នែកអប់រំ SERD |
| | R. Kausar, ប្រធានផ្នែក រដ្ឋបាលគម្រោង SERD |
| | M. Kob, អ្នកឯកទេសជាតិ ផ្នែកប្រែប្រួលអាកាសធាតុ (CARM), SERD |
| | N. LaRocque, អ្នកឯកទេសជាន់ខ្ពស់ផ្នែកអប់រំ SERD |
| | P. Long, មន្ត្រីគម្រោងជាន់ខ្ពស់ (CARM), SERD |
| | S. Mar, មន្ត្រីជាន់ខ្ពស់ផ្នែកវិស័យសង្គម (CARM), SERD |
| | C. Ouch, មន្ត្រីកម្មវិធីជាន់ខ្ពស់ (អភិបាលកិច្ច) (CARM), SERD |
| | N. Ouk, មន្ត្រីគម្រោងជាន់ខ្ពស់ (CARM), SERD |

| | |
|---|---|
| | S. Ouk, មន្ត្រីផ្នែកកិច្ចការពារសុវត្ថិភាព (CARM), SERD<br>S. Ranawana, អ្នកឯកទេសជាន់ខ្ពស់ផ្នែកធនធានធម្មជាតិ SERD<br>J. L. Gomez Reino, អ្នកឯកទេសជាន់ខ្ពស់ផ្នែកគ្រប់គ្រងសាធារណៈ SERD<br>S. Ros, មន្ត្រីសម្របសម្រួលទំនាក់ទំនងសាធារណៈ (CARM), SERD<br>K. Schelzig, អ្នកឯកទេសជាន់ខ្ពស់ផ្នែកវិស័យសង្គម SERD<br>S. Schipani, អ្នកឯកទេសជាន់ខ្ពស់ផ្នែកគ្រប់គ្រង SERD<br>V. Sin, ជំនួយការផ្នែកប្រតិបត្តិការ (CARM), SERD<br>I. Sokha, មន្ត្រីកម្មវិធី (CARM), SERD<br>S. Teoh, អ្នកឯកទេសផ្នែកធនធានធម្មជាតិ SERD<br>S. Tukuafu, ប្រធានសេដ្ឋកិច្ចវិទូ SERD<br>L. Yang, អ្នកឯកទេសផ្នែកថាមពល SERD<br>M. White, អ្នកឯកទេសផ្នែកអភិវឌ្ឍន៍តំបន់ទីក្រុង SERD |
| **ជំនួយការត្រួតពិនិត្យ** | T. Niazi,<br>អ្នកឯកទេសជាន់ខ្ពស់ផ្នែកគ្រប់គ្រងសាធារណៈនៃនាយកដ្ឋានអភិវឌ្ឍន៍តំបន់<br>និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (RSDD)<br>M. Rattinger, អ្នកឯកទេសផ្នែកប្រែប្រួលអាកាសធាតុ RSDD<br>S. Tanaka, អ្នកឯកទេសជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សង្គម RSDD<br>P. Vandenberg, សេដ្ឋកិច្ចវិទូជាន់ខ្ពស់ផ្នែកកសាងសមត្ថភាព<br>និងការបណ្តុះបណ្តាល នៃវិទ្យាស្ថាន ADB<br>B. Woods, អ្នកឯកទេសជាន់ខ្ពស់ផ្នែកគ្រប់គ្រងលទ្ធផលនៃនាយកដ្ឋានយុទ្ធសាស្ត្រ<br>និងគោលនយោបាយ |

នៅក្នុងការរៀបចំឯកសារយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសណាមួយ ការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងណាមួយ ឬ ការលើកឡើងណាមួយពាក់ព័ន្ធនឹងដែនដី ឬ តំបន់ភូមិសាស្ត្រណាមួយ នៅក្នុងឯកសារនេះ ធនាគារអភិវឌ្ឍន៍អាស៊ី ពុំមានចេតនាធ្វើការវិនិច្ឆ័យទៅលើស្ថានភាពស្របច្បាប់ ឬ ស្ថានភាពផ្សេងៗនៃដែនដី ឬ តំបន់នោះឡើយ។

# មាតិកា

ទំព័រ

**ព័ត៌មានសង្ខេបអំពីប្រទេស**

1. **និន្នាការអភិវឌ្ឍន៍ និងបញ្ហា** 1

ក .បរិបទប្រទេស ........ 1

ខ. ការវាយតំលៃ និងទស្សនវិស័យសេដ្ឋកិច្ច ........ 3

គ. ចំណុចសំខាន់ៗនៃយុទ្ធសាស្ត្រប្រចាំប្រទេសមុនៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ........ 4

2. **យុទ្ធសាស្ត្រប្រចាំប្រទេស** 6

ក.យុទ្ធសាស្ត្រជាតិរបស់រាជរដ្ឋាភិបាល ........ 6

ខ. យុទ្ធសាស្ត្រប្រចាំប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ........ 7

3. **ការអនុត្តន៍យុទ្ធសាស្ត្រ** 16

ក. គំរោងធនធាន ........ 16

ខ. ទិដ្ឋភាពទូទៅនៃកម្មវិធី ........ 16

4. **ការគ្រប់គ្រងលទ្ធផល** 17

ក. ការត្រួតពិនិត្យ ........ 17

ខ. ហានិភ័យ ........ 17

**ក្របខ័ណ្ឌលទ្ធផលនៃយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស** 19

**បញ្ជីរាយនាមឯកសារយោង** 23

# ព័ត៌មានសង្ខេបអំពីប្រទេស

| សេដ្ឋកិច្ច | 2010 | 2011 | 2012 | 2013[a] | 2014[b] |
|---|---|---|---|---|---|
| GDP (ពាន់លាន $, បច្ចុប្បន្ន) | 11.2 | 12.8 | 14.0 | 15.2 | 16.8 |
| GDP ក្នុង១នាក់ ($, បច្ចុប្បន្ន) | 805 | 902 | 968 | 1,037 | 1,125 |
| កំណើន GDP (%, ក្នុងតម្លៃថេរ) | 6.0 | 7.1 | 7.3 | 7.2 | 7.0 |
| កសិកម្ម | 4.0 | 3.1 | 4.3 | 1.8 | 4.7 |
| ឧស្សាហកម្ម | 13.6 | 14.5 | 9.2 | 10.5 | 8.7 |
| សេវាកម្ម | 3.3 | 5.0 | 8.1 | 8.4 | 7.1 |
| ការវិនិយោគក្នុងស្រុកសរុប (% នៃ GDP) | 17.3 | 22.0 | 23.5 | 23.5 | 21.5 |
| ការសន្សំក្នុងស្រុកសរុប (% នៃ GDP) | 13.4 | 13.9 | 14.8 | 14.9 | 13.1 |
| សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ (ភាគរយនៃការប្រែប្រួលប្រចាំឆ្នាំ) | 4.0 | 5.5 | 2.9 | 3.0 | 4.4 |
| រូបិយវត្ថុទូទៅ (M2) (ការប្រែប្រួលភាគរយប្រចាំឆ្នាំ) | 20.0 | 21.4 | 20.9 | 14.6 | … |
| អធិរេកហិរញ្ញវត្ថុជារួម (ឱនភាព) (% នៃ GDP) | (8.1) | (7.5) | (5.2) | (5.0) | (4.8) |
| សមតុល្យពាណិជ្ជកម្មទំនិញ (% នៃ GDP) | (14.1) | (11.6) | (14.6) | (15.7) | (15.9) |
| សមតុល្យគណនីចរន្ត (% នៃ GDP) [c] | (10.4) | (8.8) | (11.6) | (10.8) | (11.3) |
| សេវាសំណងកម្ចីបរទេស (% ការនាំចេញទំនិញ និងសេវាកម្ម) | 1.6 | 1.6 | 1.5 | 1.6 | … |
| កម្ចីបរទេស (% នៃ GDP) | 29.3 | 28.4 | 30.6 | 31.6 | 31.2 |

| ភាពក្រីក្រ និង សង្គម | ទសវត្សរ៍ឆ្នាំ 1990 | ទសវត្សរ៍ឆ្នាំ2000 | ឆ្នាំចុងក្រោយ |
|---|---|---|---|
| ចំនួនប្រជាជន (លាន) | 11.4 [1998] | 13.4 [2008] | 14.7 [2013] |
| កំណើនប្រជាជន (ភាគរយនៃការប្រែប្រួលប្រចាំឆ្នាំ) | 2.3 [1998] | 1.54 [2008] | 1.83 [2013] |
| ផលធៀបអត្រាមរណមាតា (ក្នុង ១០០.០០០ កំណើតរស់) | 437 [1997] | 472 [2005] | 206 [2010] |
| អត្រាមរណទារក (អាយុក្រោម១ឆ្នាំ ក្នុង ១.០០០ កំណើតរស់) | 95 [1998] | 65 [2005] | 45 [2010] |
| ជីវិតរស់នៅជាមធ្យមនៅពេលកើត (ឆ្នាំ) | 50 [1990] | 61 [2007] | 63.6 [2012]<br>64.3 (ស្ត្រី)<br>60.5 (បុរស) |
| អក្ខរកម្មមនុស្សពេញវ័យ (%) | 67.3 [1998] | 77.6 [2008] | 88 [2010] |
| ការចុះឈ្មោះចូលរៀនសរុបនៅកម្រិតបឋមសិក្សា (%) | 77.8 [1998] | 95.4 [2006] | 98.2 [2011] |
| កង្វះអាហារូបត្ថម្ភកុមារ (ភាគរយអាយុក្រោម៥ឆ្នាំ) | … | 43.2 [2005] | 39.9 [2010] |
| ប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ (%) | … | 47.8 [2007] | 18.9 [2013] |
| ប្រជាជនដែលទទួលបានប្រភពទឹកស្អាត (%) | 21.5 [1990] | 41.5 [2000] | 71.3 [2012] |
| ប្រជាជនដែលទទួលបានហេដ្ឋារចនាសម្ព័ន្ធអនាម័យស្អាត (%) | 2.8 [1990] | 16.3 [2000] | 36.8 [2012] |

| បរិស្ថាន | ឆ្នាំមុនៗ | ឆ្នាំចុងក្រោយ |
|---|---|---|
| ការបំភាយឧស្ម័នកាបូនិក (តោន) | 286,000 [1980] | 4,180,380 [2010] |
| ការបំភាយឧស្ម័នកាបូនិក ក្នុងមួយនាក់ (តោន) | 0.04 [1980] | 0.29 [2010] |
| តំបន់ព្រៃ (លានហិកតា) | 12.94 [1990] | 9.97 [2011] |
| ប្រជាជននៅតំបន់ទីក្រុង (ភាគនៃប្រជាជនសរុប) | 9.0 [1980] | 20.4 [2013] |

| **ផលប័ត្រ ADB (កម្ចីផ្ដល់ទៅរដ្ឋ (sovereign loan) គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤)** | **OCR** | **ADF** | **សរុប** |
|---|---|---|---|
| ចំនួនកម្ចីសរុប | 2 | 71 | 73 |
| ចំនួនទឹកប្រាក់កម្ចីសុទ្ធ (លាន $) | 83.0 | 1,686.8 | 1,769.8 |
| **ការដកសាច់ប្រាក់** | | | |
| មូលនិធិសរុបដែលមានសម្រាប់ដកប្រាក់ (លាន $) | 83.0 | 1,686.8 | 1,769.8 |
| ចំនួនទឹកប្រាក់ដែលត្រូវបានដក (លាន $) | … | 1,203.3 | 1,203.3 |
| ភាគរយនៃទឹកប្រាក់ដែលត្រូវបានដក (ចំនួនទឹកប្រាក់ដែលត្រូវបានដក/ចំនួនទឹកប្រាក់សរុបដែលមាន) | … | 71.3% | 67.9% |

… = គ្មាន, ( ) = អវិជ្ជមាន, [ ] = ឆ្នាំចុងក្រោយបំផុតដែលមានទិន្នន័យ, ADB = ធនាគារអភិវឌ្ឍន៍អាស៊ី, ADF = មូលនិធិអភិវឌ្ឍន៍អាស៊ី, GDP = ផលិតផលក្នុងស្រុកសរុប, M2 = ថវិកាទូលំទូលាយ, OCR = ធនធានមូលធនធម្មតា។

[a] ការប៉ាន់ប្រមាណ។

[b] ការព្យាករណ៍។

[c] មិនរាប់បញ្ចូលការផ្ទេរជាផ្លូវការ។

ប្រភព ៖ រាជរដ្ឋាភិបាលកម្ពុជា, ទិន្នន័យនៃទស្សនវិស័យអភិវឌ្ឍន៍អាស៊ី, កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និង ធនាគារពិភពលោក។

# ១. និន្នាការអភិវឌ្ឍន៍ និងបញ្ហា

## ក.បរិបទប្រទេស

1. កម្ពុជាកំពុងប្រែក្លាយខ្លួនពីប្រទេសដែលធ្លាប់បានរងគ្រោះដោយសារសង្គ្រាមរាំរ៉ៃទៅជាប្រទេសមួយដែលមានសេដ្ឋកិច្ចផ្តោតលើទីផ្សារ តាមរយៈ កំណែទម្រង់ដែលមានស្ថេរភាព និងទូលំទូលាយ។ ការកសាងប្រទេសបានចាប់ផ្តើមពីមូលដ្ឋានមួយដែលមានកម្រិតទាបខ្លាំងដែលជាលទ្ធផលនៃសង្គ្រាមរាំរ៉ៃ ដែលបានបង្កឲមានការបាត់បង់ជីវិត ធនធានមនុស្ស និងសម្បត្តិជាតិជាច្រើន។ សន្តិភាព និង ស្ថេរភាពនយោបាយត្រូវបានបង្កើតឡើងវិញក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនាឆ្នាំ១៩៩១។ រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បានបើកផ្លូវឲមានការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ និង សេដ្ឋកិច្ចទីផ្សារសេរី។ ក្រោយការបោះឆ្នោតថ្នាក់ជាតិដែលបានប្រព្រឹត្តធ្វើឡើងក្នុងខែកក្កដា ឆ្នាំ២០១៣ ភាពតានតឹងផ្នែកនយោបាយបានអូសបន្លាយអស់រយៈពេល១ឆ្នាំ ប៉ុន្តែក្រោយមកស្ថានភាននយោបាយក៏មានស្ថេរភាពឡើងវិញ។ ត្បិតថាសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងទៅលើតំបន់ជនបទ និងមានមូលដ្ឋានកំណើនសេដ្ឋកិច្ចតូចចង្អៀត (វិស័យកាត់ដេរ ទេសចរណ៍ កសិកម្ម និងសំណង់) ហើយអភិបាលកិច្ចនិងតម្លាភាពនៅមានកំរិតនៅឡើយ សមិទ្ធិកម្មសេដ្ឋកិច្ចកម្ពុជាមានការរីកចំរើនគួរឲចាប់អារម្មណ។ ការអនុវត្តន៍ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១០ និងការបង្កើតឲមានអង្គភាពប្រឆាំងអំពើពុករលួយជាកិច្ចខិតខំដែលបានបង្ហាញឲឃើញនាពេលថ្មីៗនេះ។ ប្រទេសកម្ពុជាមានអំណោយផលល្អក្នុងការទាញយកប្រយោជន៍ពីកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់ (RCI) និង ការតភ្ជាប់ទំនាក់ទំនងនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ (GMS) ហើយប្រទេសនេះ ក៏កំពុងត្រៀមខ្លួនដើម្បីទប់ទល់នឹងបញ្ហាប្រឈមនានាជុំវិញសមាហរណកម្មសេដ្ឋកិច្ចតំបន់នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៥។

2. **ភាពក្រីក្រ ៖** តួលេខផ្លូវការបង្ហាញឲឃើញថា ភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា បានធ្លាក់ចុះយ៉ាងគំហុកពី ៤៧,៨% ក្នុងឆ្នាំ២០០៧ មកត្រឹម ១៨,៩% ក្នុងឆ្នាំ២០១២[1]។ ភាពក្រីក្របានធ្លាក់ចុះខ្លាំងជាងគេនៅចន្លោះឆ្នាំ២០០៧-២០០៩ ប៉ុន្តែល្បឿននៃការធ្លាក់ចុះបានបន្ថយនៅចន្លោះឆ្នាំ២០០៩-២០១២។ ភាពក្រីក្រនៅតាមទីក្រុងនានា បានកើនឡើង នៅចន្លោះឆ្នាំ២០១០-២០១១ ប៉ុន្តែ បានធ្លាក់ចុះមកវិញ ក្នុងឆ្នាំ២០១២។ អត្រាភាពក្រីក្រមានកម្រិតខ្ពស់បំផុតនៅតំបន់ជនបទ (១៩,៩% ក្នុងឆ្នាំ២០១២) ដែល ៩នាក់ ក្នុងចំណោម១០នាក់ជាជនក្រីក្រ ។ ទោះបីថាអត្រានៃភាពក្រីក្របានធ្លាក់ចុះយ៉ាងឆាប់រហ័ស និងគំលាតនៃវិសមភាពត្រូវបានបង្រួមចុះក៏ដោយ ក៏ប្រជាជនមួយភាគធំនៅតែបន្តប្រឈមនឹងភាពងាយធ្លាក់ខ្លួនក្រវិញ ដោយហេតុថាពួកគេបានត្រឹមតែរើខ្លួនរួចពីក្រោមខ្សែបន្ទាត់ភាពក្រីក្របន្តិច មកស្ថិតនៅត្រឹមលើខ្សែបន្ទាត់ភាពក្រីក្រតែបន្តិចប៉ុណ្ណោះ។ នាឆ្នាំ២០១១ មានប្រជា-ពលរដ្ឋកម្ពុជាចំនួន ១0% មានសមត្ថភាពចំណាយតិចជាង ១,២៥ ដុល្លារក្នុងមួយថ្ងៃ ប៉ុន្តែ ៤១% មានសមត្ថភាពចំណាយតិចជាង ២ដុល្លារក្នុងមួយថ្ងៃ ហើយ៧២% មានសមត្ថភាពចំណាយតិចជាង ៣ដុល្លារ ក្នុងមួយថ្ងៃ[2]។ អាស្រ័យដោយមានគ្រួសារជាច្រើនកំពុងរស់នៅត្រឹមលើខ្សែបន្ទាត់ភាពក្រីក្រជាតិតែបន្តិចប៉ុណ្ណោះ

---

[1] ក្នុងឆ្នាំ២០១៣ ក្រសួងផែនការបានប្រកាន់យកខ្សែបន្ទាត់ភាពក្រីក្រផ្លូវការថ្មី និង បានកែសម្រួលតម្លើងការប៉ាន់ប្រមាណភាពក្រីក្រសម្រាប់ឆ្នាំ២០០៤ និងឆ្នាំ២០០៧ ព្រមជាមួយនឹងតួលេខថ្មីសម្រាប់ឆ្នាំ២០០៨-២០១១ ដោយផ្អែកលើការអង្កេតសង្គមសេដ្ឋកិច្ចនៅកម្ពុជា។ សូមមើលការវិភាគអំពីភាពក្រីក្រ (សង្ខេប) (អាចរកមើលបានពីបញ្ជីរាយនាមឯកសារដែលបានភ្ជាប់ក្នុងឧបសម្ព័ន្ធ២)។

[2] ផ្អែកលើសម្ពត្តភានៃការចំណាយនាឆ្នាំ២០០៥។

ដូច្នេះពួកគាត់ងាយធ្លាក់ខ្លួនទៅក្នុងភាពក្រីក្រវិញបំផុត សូម្បីតែវិបត្តិតូចតាចក៏អាចទាញពួកគាត់ទម្លាក់ធ្លាក់ក្នុងភាពក្រីក្រវិញបានយ៉ាងងាយ។ ក្នុងខណៈពេលដែលគ្មានប្រព័ន្ធគាំពារសង្គមពេញលេញ អត្រាកង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារមានកម្រិតខ្ពស់ ហើយមានគ្រួសារក្រីក្រជាច្រើនខ្ចីបុលគេដើម្បីត្រឹមយកមកដោះស្រាយជីវភាពប្រចាំថ្ងៃប៉ុណ្ណោះ ។

3. **សមធម៌យេនឌ័រ ៖** ផ្នត់គំនិតជុំវិញតួនាទីរបស់ស្ត្រីក្នុងសង្គមកម្ពុជា នៅតែបន្តជាបញ្ហាប្រឈមចំពោះសមធម៌យេនឌ័រក្នុងប្រទេសនេះ។ នាឆ្នាំ២០១០ ខណៈពេលដែល ៨៤% នៃស្ត្រីដែលមានអាយុចន្លោះពី ១៥-៦៤ ឆ្នាំ បានចូលរួមក្នុងកំលាំងពលករ ក្នុងនោះមានស្ត្រី ៥៥% ធ្វើការក្នុងវិស័យកសិកម្ម ដែលសមាមាត្រនេះ មានកម្រិតថេរបន្តរតាំងពីឆ្នាំ២០០៤ មក។ សមាមាត្រនៃស្ត្រីដែលបានចូលរួមបម្រើការងារនៅក្នុងវិស័យឧហ្សាហកម្ម និងសេវាកម្មក៏បានមានការប្រែប្រួលបន្តិចបន្តួចផងដែរ។ ក្នុងចំណោមពលករដែលធ្វើការងារទទួលបានបៀវត្សរ៍ក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ ពលករជាស្ត្រីមានចំនួនតែត្រឹម ២៧% ប៉ុណ្ណោះ ដែលពួកគាត់ភាគច្រើនធ្វើការក្នុងឧស្សាហកម្មកាត់ដេរ ដែលមានភាពងាយរងគ្រោះ និង ទទួលបានបៀវត្សរ៍ទាប។ គម្លាតយេនឌ័រក្នុងការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យត្រូវបានបង្រួញ ហើយអត្រាអក្ខរភាពមានការកើនឡើង បើទោះបីជាវប្បធម៌សង្គម និង សេដ្ឋកិច្ចនៅតែបន្តរជាឧបសគ្គចំពោះការអប់រំរបស់កុមារីក៏ដោយ។ កុមារីនៅតែបោះបង់ការសិក្សាក្នុងកម្រិតមួយខ្ពស់ជាងកុមារា ដែលភាគច្រើនបណ្តាលមកពីមូលហេតុសេដ្ឋកិច្ច។

4. **គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា** ៖ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តសម្រេចឲបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (MDG) នៅឆ្នាំ២០១៥ ប៉ុន្តែ វឌ្ឍនភាពមានលទ្ធផលចំរុះ។ កម្ពុជាគឺជាប្រទេសមួយដែលសម្រេចគោលដៅបានមុនពេលកំណត់នៅក្នុងវិស័យជាច្រើន ដូចជា ក្នុងការកាត់បន្ថយភាពក្រីក្រ ការបង្កើនការចុះឈ្មោះចូលរៀនកម្រិតបឋមសិក្សា និង ការប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ និង ជម្ងឺរបេង។ សូចនាករដែលទំនងនឹងសម្រេចបាននាឆ្នាំ២០១៥ រួមមាន អត្រាបញ្ចប់ការអប់រំកម្រិតបឋមសិក្សា និង សមាមាត្រយេនឌ័រនៅក្នុងការអប់រំកម្រិតមធ្យមសិក្សា។ បើទោះជាដូច្នេះក្តី អត្រាចុះឈ្មោះចូលរៀនជារួមនៅកម្រិតមធ្យមសិក្សានៅមានកម្រិតទាប។ វឌ្ឍនភាពមានភាពយឺតយ៉ាវក្នុងកាត់បន្ថយកង្វះអាហារូបត្ថម្ភកុមារ អត្រាមរណរបស់ទារកនិងកុមារ និងការផ្តល់លទ្ធភាពឱ្យទទួលបានអនាម័យមូលដ្ឋាន។ គោលដៅទាំងនេះ មិនត្រូវបានរំពឹងថា នឹងសម្រេចទាន់ពេលវេលាឡើយ។ ការគ្របដណ្តប់ផ្នែកអនាម័យមានកម្រិតទាបនៅតាមតំបន់ជនបទ។ នាឆ្នាំ២០១១ មានគ្រួសារចំនួនតែ២២% ប៉ុណ្ណោះដែលមានបង្គន់ប្រើប្រាស់។ គំរបព្រៃឈើចំនួន ៥៧% មានកម្រិតទាបជាងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍បន្តិច ដែលបានកំណត់ត្រឹម ៦០% ។ ជាមួយនឹងការបែងចែកប្រភេទព្រៃឈើ ដោយរាប់បញ្ចូលចម្ការមួយចំនួន ដូចជា ចម្ការកៅស៊ូ ដូងប្រេង និង ដើមប្រេងខ្យល់ ប្រទេសកម្ពុជា ទំនងនឹងអាចសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ក្នុងឆ្នាំ២០១៥[3]។

[3] ការវាយតម្លៃបរិស្ថាន (សង្ខេប) (អាចរកមើលបានពីបញ្ជីរាយនាមឯកសារដែលត្រូវបានភ្ជាប់ក្នុងឧបសម្ព័ន្ធ២)។

### ខ. ការទាយតំលៃ និងទស្សនវិស័យសេដ្ឋកិច្ច

5. **សមិទ្ធិកម្មសេដ្ឋកិច្ច** ៖ ក្នុងអំឡុងឆ្នាំ២០១១-២០១៣ ខណៈពេលដែលប្រទេសកម្ពុជាបានបោះជំហានខិតទៅកាន់តែជិតជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប[4] កំណើនសេដ្ឋកិច្ចរបស់ប្រទេសបានកើនឡើងលើស ៧% ក្នុងមួយឆ្នាំ ដែលអត្រានេះមានការរុញច្រានពីសមិទ្ធិកម្មរឹងមាំក្នុងវិស័យឧស្សាហកម្ម សេវាកម្ម និង កសិកម្ម[5]។ អត្រាកំណើននេះត្រូវបានរំពឹងថានឹងបន្តក្នុងឆ្នាំ២០១៥-២០១៦ លើកលែងតែមានវិបត្តិពីកត្តាខាងក្រៅ។ ការវិនិយោគដោយផ្ទាល់ពីបរទេសបានដើរតួនាទីកាន់តែសំខាន់ក្នុងការអភិវឌ្ឍន៍ឧស្សាហកម្ម ដោយតម្លៃវិនិយោគបានកើនឡើងរហូតដល់ ១,២ពាន់លានដុល្លារ ក្នុងឆ្នាំ២០១៣។ ការហូរចូលនៃការវិនិយោគកំពុងគាំទ្រដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធដ៏ឆាប់រហ័សនៃសេដ្ឋកិច្ច ពីសកម្មភាពដែលមានការបន្ថែមគុណតម្លៃទាប ដូចជាវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងផលិតកម្មស្រូវដែលមានទិន្នផលទាបជាដើម ទៅជាសមាហរណកម្មទៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សកលដែលមានការបន្ថែមគុណតម្លៃខ្ពស់ជាងមុន ដូចជាឧស្សាហកម្មគ្រឿងបន្លាស់រថយន្ត និងគ្រឿងអេឡិចត្រូនិក និង សកម្មភាពកសិកម្មដែលមានការបន្ថែមគុណតម្លៃខ្ពស់ជាដើម។ យ៉ាងណាមិញ បើទោះបីជាមានសញ្ញាណបឋមនៃពិពិធកម្មសេដ្ឋកិច្ចនៅក្នុង និង លើសពីវិស័យទាំងបួន ដែលបានជម្រុញកំណើនសេដ្ឋកិច្ចកន្លងមកក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជានៅតែបន្តមានភាពងាយរងគ្រោះទៅនឹងវិបត្តិខាងក្រៅ និងគ្រោះធម្មជាតិនានាផងដែរ។

6. **ឧបសគ្គដែលរាំងស្ទះ កំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា** ៖ ការសិក្សាវិនិច្ឆ័យប្រចាំប្រទេសកម្ពុជា (CDS) បានកំណត់រកឃើញឧបសគ្គចម្បងៗចំនួនប្រាំ ដែលរាំងស្ទះចំពោះកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា៖ (១) មូលធនមនុស្ស៖ ប្រជាជនមានការអប់រំទាប និងកម្លាំងការងារមានជំនាញមិនគ្រប់គ្រាន់ (២) ការផ្គត់ផ្គង់អគ្គិសនី៖ បរិមាណអគ្គិសនីសម្រាប់ផ្គត់ផ្គង់នៅមានកម្រិត មានតម្លៃថ្លៃ និង មិនអាចគួរឱ្យជឿជាក់បាន ជាពិសេស នៅតាមតំបន់ជនបទ (៣) បណ្តាញគមនាគមន៍៖ ផ្លូវថ្នល់ជនបទមិនល្អ និង មិនមានផែនិងបណ្តាញផ្លូវទឹកគ្រប់គ្រាន់ (៤) អំពើពុករលួយ និងអភិបាលកិច្ចមានកម្រិតទាប និង (៥) ការទទួលបានសេវាសុខភាព ទឹក និងអនាម័យនៅមានកម្រិតទាប ជាពិសេសនៅក្រៅរាជធានីភ្នំពេញ[6]។

7. ស្របគ្នាទៅនឹងការសិក្សាវិនិច្ឆ័យប្រចាំប្រទេសកម្ពុជា លទ្ធផលនៃការអង្កេតសង្គមសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាឆ្នាំ២០១៣ បានបង្ហាញឱ្យដឹងថា កម្លាំងការងារចំនួន ៨៧% មានការអប់រំត្រឹមកម្រិតបឋមសិក្សា ហើយមូលធនមនុស្សប្រឈមនឹងគុណភាពអប់រំទាប កង្វះជំនាញ និង ការងារមិនត្រូវជំនាញ នៅក្នុងទីផ្សារការងារ។ បញ្ហាប្រឈមដែលទាក់ទងទៅនឹងការផ្គត់ផ្គង់អគ្គិសនី ឆ្លុះបញ្ចាំងឲឃើញអំពីការគ្របដណ្តប់អគ្គិសនី ដែលមានកម្រិតទាប និង មានតម្លៃខ្ពស់។ បើទោះជាដូច្នេះក្តី គម្រោងផលិតថាមពលមួយចំនួនដែលមានការគាំទ្រពីដៃគូ

---

[4] ប្រទេសកម្ពុជាត្រូវបានរំពឹងថា នឹងឈានដល់កម្រិតប្រាក់ចំណូលមធ្យមកម្រិតទាបចំនួន ១.០៤៥ដុល្លារ នៃប្រាក់ចំណូលជាតិសរុបក្នុងមួយនាក់ ក្នុងឆ្នាំ២០១៤ ឬ ឆ្នាំ២០១៥ ដែលចំនួននេះ ត្រូវបានគណនាតាមវិធីសាស្ត្រ Atlas របស់ធនាគារពិភពលោក។ ប្រាក់ចំណូលជាតិសរុបក្នុងមួយនាក់ មានចំនួន ៩៥០ដុល្លារ ក្នុងឆ្នាំ២០១៣។

[5] ការវិភាគសេដ្ឋកិច្ច (សង្ខេប) (អាចរកមើលបានពីបញ្ជីរាយនាមឯកសារដែលបានភ្ជាប់ក្នុងឧបសម្ព័ន្ធ២)។ វិស័យកាត់ដេរបន្តមានដំណើរការល្អនៅក្នុងទីផ្សារសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក កំណើននៃការមកដល់របស់ភ្ញៀវទេសចរជាមធ្យមមានចំនួនជិត ២០% ក្នុងមួយឆ្នាំ ហើយវិស័យកសិកម្មបានកើនឡើងជាមធ្យមប្រមាណ ៣% ក្នុងមួយឆ្នាំ បើទោះបីជាហេតុការណ៍ទឹកជំនន់មានការកើនឡើងក៏ដោយ។

[6] ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ឆ្នាំ២០១៤។ ប្រទេសកម្ពុជា៖ ឧបសគ្គសំខាន់ៗដែលរាំងស្ទះដល់ការអភិវឌ្ឍន៍៖ការសិក្សាវិនិច្ឆ័យប្រចាំប្រទេស។ ទីក្រុងម៉ានីល (សេចក្តីព្រាង)។ សេចក្តីសង្ខេបអាចរកមើលបានពីបញ្ជីរាយនាមឯកសារដែលបានភ្ជាប់ក្នុងឧបសម្ព័ន្ធ២។

អភិវឌ្ឍន៍ដទៃទៀត ត្រូវបានរំពឹងថា នឹងជួយកែសម្រួលទៅលើការផ្គត់ផ្គង់ និងការគ្របដណ្តប់អគ្គិសនី ព្រមទាំងកាត់បន្ថយតម្លៃអគ្គិសនីផងដែរ។ ស្ថានភាពមិនល្អនៅតាមផ្លូវលំជាតិ ផ្លូវលំខេត្ត និងផ្លូវលំជនបទ គឺជាចំណុចខ្សោយចម្បងនៃប្រព័ន្ធដឹកជញ្ជូនតាមផ្លូវថ្នល់។ កម្ពុជាមានអត្រាភាគរយផ្លូវក្រាលកៅស៊ូនិងផ្លូវចាក់បេតុងទាបបំផុតក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន។ អំពើពុករលួយនៅតែបន្តចាត់ទុកថា ជាចំណុចដែលគួរឲព្រួយបារម្ភសម្រាប់បរិយាកាសធុរកិច្ច និង អភិបាលកិច្ចទូទៅក្នុងប្រទេសកម្ពុជា។

8. **វិស័យឯកជន** ៖ ការចូលរួមចំណែកនៃវិស័យឯកជននៅក្នុងសេដ្ឋកិច្ចមានចំនួនជាង ៨០%។ វិស័យនេះភាគច្រើនជាសហគ្រាស និង កសិដ្ឋានក្រៅប្រព័ន្ធដែលមានទំហំតូច ហើយសហគ្រាសទំនើបធំៗមានតែមួយចំនួនតូចប៉ុណ្ណោះ។ ក្រុមហ៊ុនដែលមានប្រតិបត្តិការស្ថិតនៅចន្លោះប្រភេទសហគ្រាសទាំងពីរមុននេះមានចំនួនតិចតួចប៉ុណ្ណោះ។ កង្វះខាតនេះ ជាចំណុចខ្សោយមួយនៅក្នុងរចនាសម្ព័ន្ធវិស័យឯកជន ទាំងនៅតំបន់ជនបទ និងតំបន់ទីក្រុង ដែលជាកត្តារាំងស្ទះដល់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ និងពិពិធកម្មសេដ្ឋកិច្ច។ បើទោះបីជាបរិយាកាសធុរកិច្ចបានមានភាពប្រសើរឡើងក៏ដោយ នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើដើម្បីទាក់ទាញការវិនិយោគ និងបង្កើតឲមាននូវការងារដែលមានផលិតភាពខ្ពស់ និង ទទួលបានបៀវត្សរ៍ខ្ពស់ សម្រាប់កម្លាំងការងារដែលកំពុងមានចំនួនកាន់តែច្រើនឡើងក្នុងប្រទេសនេះ។ នៅក្នុងការអង្កេតស្តីពីបរិយាកាសវិនិយោគ ឆ្នាំ២០១២ សហគ្រាសទាំងអស់ រាប់បញ្ចូលទាំង សហគ្រាសសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ បានដាក់ពិន្ទុទៅលើឧបសគ្គរាំងស្ទះការវិនិយោគដូចតទៅ ការទទួលបានអគ្គិសនីប្រើប្រាស់ និងតម្លៃអគ្គិសនីជាឧបសគ្គធំជាងគេ (៤២%), បន្ទាប់មកគឺក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច (៣៩%), អំពើពុករលួយ (២៨%), ការដឹកជញ្ជូន(២៤%), សកម្មភាពរារាំងការប្រកួតប្រជែងនានា (២៣%), តម្លៃនៃហិរញ្ញប្បទាន (២៣%), ហើយ ជំនាញ និងការអប់រំ (២០%)។

## គ. ចំណុចសំខាន់ៗនៃយុទ្ធសាស្ត្រប្រចាំប្រទេសមុនៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

9. យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស (CPS) សម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១១-២០១៣ របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានសង្កត់ធ្ងន់ទៅលើការកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកកម្ពស់កំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍន៍សង្គម និងសមធម៌។ យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសផ្តោតអាទិភាពទៅលើវិស័យចំនួនប្រាំ ដែលរួមមាន ៖ គមនាគមន៍ (ផ្លូវជនបទ និងផ្លូវខេត្ត), ធនធានទឹក អនាម័យ និងការអភិវឌ្ឍន៍តំបន់ទីក្រុង, កសិកម្ម និងធនធានធម្មជាតិ (កសិពាណិជ្ជកម្មភាវូបនិយកម្ម និង ប្រព័ន្ធធារាសាស្ត្រ), វិស័យអប់រំ (កម្រិតអនុវិទ្យាល័យ និង ផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ), និង វិស័យហិរញ្ញវត្ថុ (និយ័តកម្មធនាគារហិរញ្ញប្បទានសម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម [SME] និង មីក្រូហិរញ្ញវត្ថុ)។ ព្រមជាមួយគ្នានោះធនាគារអភិវឌ្ឍន៍អាស៊ីក៏ផ្តោតលើវិស័យពីរទៀតដែលគាំទ្រវិស័យទាំងប្រាំខាងលើគឺ៖ ការគ្រប់គ្រងវិស័យសាធារណៈ (PSM) , ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) និងវិមជ្ឈការនិងវិសហមជ្ឈការ (D&D)។ កម្មវិធីនោះបានឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃបម្រែបម្រួលអាកាសធាតុ, វិមជ្ឈការ និង វិសហមជ្ឈការ, ការតភ្ជាប់ទំនាក់ទំនងរវាងតំបន់ជនបទ និងតំបន់ទីក្រុង, និងកិច្ចសហប្រតិបត្តិការតំបន់។ កម្មវិធីនោះ ក៏បានឆ្លើយតបទៅនឹងកាតាលិករអភិវឌ្ឍន៍ទាំងប្រាំគឺ ការអភិវឌ្ឍន៍វិស័យឯកជន (PSD), អភិបាលកិច្ច, សមធម៌យេនឌ័រ, ការចែករំលែកចំណេះដឹង និង ភាពជាដៃគូផងដែរ។

10. ការវាយតំលៃនៃយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសឆ្នាំ២០១១-២០១៣ បានរកឃើញថា ការអនុវត្តន៍យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសឆ្នាំ២០១១-២០១៣ ទទួលបានលទ្ធផលគួរជាទីពេញចិត្ត។ ការវាយតំលៃនោះ ក៏បានរកឃើញនូវអនុសាសន៍ដើម្បីត្រួសត្រាយការរៀបចំយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសថ្មីដូចតទៅ៖ (១) បន្តផ្តោតទៅលើវិស័យសំខាន់ៗ និងកាតាលិករអភិវឌ្ឍន៍នានាដើម្បីជំរុញឲមានកំណែទម្រង់ឲបានស៊ីជម្រៅ ពង្រឹងសមត្ថភាពអភិវឌ្ឍន៍ និងពង្រឹងសមត្ថភាពទាញយកផលប្រយោជន៍ឲបានកាន់តែច្រើនបន្ថែមទៀតពីសមាហរណកម្មតំបន់ (២) ពិចារណារកយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យ និងសម្រាប់ឆ្លើយតបភ្លាមៗនឹងគ្រោះមហន្តរាយដែលបណ្តាលមកពីគ្រោះទឹកជំនន់ ឬ គ្រោះរាំងស្ងួតធ្ងន់ធ្ងរ (៣) រៀបចំយុទ្ធសាស្ត្រចែករំលែកចំណេះដឹងដ៏ក្បោះក្បាយមួយ ដើម្បីត្រួសត្រាយសកម្មភាពនានារបស់យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស និង (៤) ធានាថាយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសមានមូលដ្ឋានផ្អែកលើលទ្ធផលនៃការវាយតម្លៃដែលត្រូវធ្វើឡើងទៀងទាត់។ ក្រុមអ្នកវាយតម្លៃឯករាជ្យរបស់នាយកដ្ឋានវាយតម្លៃឯករាជ្យ (IED) បានវាយតម្លៃការអនុវត្តន៍យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសឆ្នាំ២០១១-២០១៣ ថា *មិនសូវគួរជាទីពេញចិត្ត*[7]។ ព្រមពេលដែលក្រុមអ្នកវាយតម្លៃឯករាជ្យឯកភាពថា ការផ្តោតជាយុទ្ធសាស្ត្រលើវិស័យនានាដែលយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស បានជ្រើសរើសមានលក្ខណៈសមស្របនឹងស្ថានភាពប្រទេសកម្ពុជា ពួកគេក៏បានផ្តល់អនុសាសន៍ឲមានវិធានការច្បាស់លាស់ជាងនេះ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងកែលម្អក្របខ័ណ្ឌលទ្ធផល ដើម្បីលើកកំពស់ប្រសិទ្ធភាព និរន្តរភាព និងសមិទ្ធផលអភិវឌ្ឍន៍ឲបានកាន់តែប្រសើរ។ រាល់អនុសាសន៍ទាំងអស់ពីរបាយការណ៍ពិនិត្យផ្ទៀងផ្ទាត់របស់ក្រុមអ្នកវាយតម្លៃឯករាជ្យ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសឆ្នាំ២០១៤-២០១៨។ សមត្ថភាពស្ថាប័ន នឹងត្រូវបន្តពង្រឹងតាមរយៈការបន្តគាំទ្រដល់ការគ្រប់គ្រងវិស័យសាធារណៈដែលនឹងនាំទៅដល់កំណែលម្អអភិបាលកិច្ចនៅកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកម្រិតមុខព្រួញ។ ក្របខ័ណ្ឌលទ្ធផលយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសថ្មីត្រូវបានពង្រឹងដោយផ្តោតលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ ២០១៤-២០១៨។ ក្របខ័ណ្ឌលទ្ធផលយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសថ្មីនេះ នឹងត្រូវយកមកប្រើប្រាស់ដើម្បីត្រួតពិនិត្យលទ្ធផលឲបានទៀងទាត់ ដែលក្នុងនោះមានទាំងការត្រួតពិនិត្យលទ្ធផលនៃការពង្រឹងសមត្ថភាពស្ថាប័នផងដែរ។ ក្របខ័ណ្ឌលទ្ធផលយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសថ្មីនេះ នឹងត្រូវបានប្រើប្រាស់សំរាប់បើការរៀបចំយុទ្ធសាស្ត្រថ្នាក់ជាតិ និង យុទ្ធសាស្ត្រវិស័យផងដែរ។

11. ក្នុងឆ្នាំ២០១៣ ទំហំនៃប្រតិបត្តិការក្នុងប្រទេសកម្ពុជារបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលរួមមានគម្រោងកម្ចី ជំនួយឥតសំណង និងជំនួយបច្ចេកទេស ដែលកំពុងអនុវត្ត មានចំនួនទឹកប្រាក់រហូតដល់១ពាន់លានដុល្លារ។ បើទោះបីជាសមាមាត្រនៃគម្រោងដែលត្រូវបានដាក់ពិន្ទុថា *មានលក្ខណៈគួរជាទីពេញចិត្ត* មានការកើនឡើងជាបន្តបន្ទាប់ក៏ដោយ ផលធៀបនៃការដកសាច់ប្រាក់ ប្រៀបធៀបទៅនឹងប្រទេសដែលមានប្រតិបត្តិការដែលមានទំហំធំជាងនេះ នៅមានកម្រិតទាបជាងមធ្យមភាគរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅឡើយ។ ការត្រួតពិនិត្យរួមគ្នាលើសមិទ្ធិកម្មប្រតិបត្តិការប្រចាំប្រទេសបានរកឃើញបញ្ហាសំខាន់ៗទាក់ទងនឹងសមិទ្ធិកម្មប្រតិបត្តិការមួយចំនួនដូចតទៅ៖ (១) សមត្ថភាពអនុវត្តរបស់ទីភ្នាក់ងារប្រតិបត្តិនៅមានកំរិត ជាពិសេសលើផ្នែកគ្រប់គ្រងគម្រោង លទ្ធកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុ (២) កង្វះខាតការផ្ទេរសិទ្ធិអំណាចទៅឲអង្គភាពគ្រប់គ្រងគម្រោង (៣) ការចាប់ផ្តើមអនុវត្ត

[7] របាយការណ៍នៃការផ្ទៀងផ្ទាត់ទៅលើការវាយតម្លៃលើកចុងក្រោយនៃយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស ឆ្នាំ២០១១-២០១៣ (អាចរកមើលបានពីបញ្ជីរាយនាម ឯកសារក្នុងឧបសម្ព័ន្ធ២)។

គម្រោងមានភាពយឺតយ៉ាវ និង (៤) ការរៀបចំគម្រោងនៅមានភាពអន់ខ្សោយ។ ចំណុចខ្វះខាតទាំងនេះ នឹងត្រូវដោះស្រាយតាមរយៈយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសថ្មី ដោយការបន្តធ្វើផែនការសកម្មភាពរួម ដើម្បី (១) កែលម្អទៅលើការរៀបចំគម្រោងតាមរយៈការអនុវត្តន៍សកម្មភាពរៀបចំឲ្យរួចរាល់គ្រប់សព្វ (readiness filters) និងការរៀបចំទុកឱ្យបានល្អជាមុន (២) បន្តការពារហានិភ័យផ្សេងៗតាមរយៈការកែលម្អគុណភាពរបាយការណ៍សវនកម្ម និងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និង (៣) ពង្រឹងសមត្ថភាពរបស់ទីភ្នាក់ងារប្រតិបត្តិ និងទីភ្នាក់ងារអនុវត្តតាមរយៈការបណ្តុះបណ្តាលអំពីនីតិវិធីប្រតិបត្តិបទដ្ឋានរបស់រដ្ឋាភិបាលសម្រាប់គម្រោងដែលទទួលបានមូលនិធិគាំទ្រពីខាងក្រៅ និងតាមរយៈការត្រួតពិនិត្យ និងវាយតម្លៃ (M&E)។

# ២. យុទ្ធសាស្ត្រប្រចាំប្រទេស

## ក.យុទ្ធសាស្ត្រជាតិរបស់រាជរដ្ឋាភិបាល

12. យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជាដំណាក់កាលទី៣ (RSIII) ចែងអំពីគោលនយោបាយអភិវឌ្ឍន៍សម្រាប់នីតិកាលទី៥នៃរដ្ឋសភា(២០១៣-២០១៨)។ រាជរដ្ឋាភិបាលមើលឃើញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ថជា"មគ្គុទេសក៍ច្បាស់លាស់ សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួរអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅបន្ត និងពង្រឹងកិច្ចអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់រយៈពេលវែង សំដៅជំរុញកំណើនសេដ្ឋកិច្ច, បន្តរបង្កើតការងារ, បែងចែកផលនៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធានាឲបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធានគ្រប់ប្រភេទ"។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ដែលយកយុទ្ធសាស្រចតុកោណដំណាក់កាលទី៣មកដំណើរការ មានគោលបំណងរួមក្នុងការកាត់បន្ថយភាពក្រីក្រមកប្រមាណ ១៥% ត្រឹមឆ្នាំ២០១៨[8]។ កាតាលិករ និង សមាសធាតុយុទ្ធសាស្ត្រចម្បងៗ រួមមានដូចខាងក្រោម ៖

(១) **អភិបាលកិច្ចល្អ (កំណែទម្រង់ស្នូល) ៖** (ក) ការប្រយុទ្ធប្រឆាំងអំពើពុករលួយ (ខ) កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (គ) កំណែទម្រង់រដ្ឋបាលសាធារណៈ រាប់បញ្ចូលការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ និង (ឃ) កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។

(២) **កសិកម្ម ៖** (ក) ការលើកកម្ពស់ផលិតភាពកសិកម្ម ពិពិធភាវូនីយកម្ម និង ពាណិជ្ជូបនីយកម្ម (ខ) កំណែទម្រង់ដីធ្លី និងការបោសសំអាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម (គ) ការលើកកម្ពស់ការចិញ្ចឹមសត្វ និង វារីវប្បកម្ម និង (ឃ) ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។

(៣) **ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៖** (ក) ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធនៅទីក្រុង (ខ) ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ (គ) ការអភិវឌ្ឍន៍ថាមពលអគ្គិសនី និង (ឃ) ការអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ។

(៤) **ការអភិវឌ្ឍន៍វិស័យឯកជន និងការងារ ៖** (ក) ការពង្រឹងវិស័យឯកជន និងការជំរុញការវិនិយោគ

[8] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ ត្រូវបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៤។

និងធុរកិច្ច (ខ) ការអភិវឌ្ឍន៍ឧស្សាហកម្ម និង សហគ្រាសធុនតូច និងមធ្យម (គ) ការអភិវឌ្ឍន៍ទីផ្សារការងារ និង (ឃ) ការអភិវឌ្ឍន៍វិស័យធនាគារ និងហិរញ្ញវត្ថុ។

(៥) **ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស** ៖ (ក) ការពង្រឹងនិងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការបណ្តុះបណ្តាលបច្ចេកទេស (ខ) ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ (គ) ការអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គម និង (ឃ) ការជំរុញអនុវត្តគោលនយោបាយជាតិប្រជាជន និង សមធម៌យេនឌ័រ។

(៦) **ការបង្កើតឲមាននូវបរិយាកាសអំណោយផលសម្រាប់ការអនុវត្តន៍ប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី៣** ៖ (ក) ការធានាចីរភាពនៃសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខនិងសណ្តាប់ធ្នាប់សង្គម (ខ) សមាហរណកម្មទៅក្នុងតំបន់ និងពិភពលោក (គ) បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះនិង ចីរភាពបរិស្ថាន និង (ឃ) ភាពជាដៃគូនៅក្នុងការអភិវឌ្ឍន៍។

13. **ការណែនាំរបស់រាជរដ្ឋាភិបាល** ៖ រាជរដ្ឋាភិបាលបានបង្ហាញនូវអាទិភាពគោលនយោបាយថ្មីៗចំនួនបីដែលយកការអភិវឌ្ឍន៍របស់ប្រទេសជាគោល ៖ (១) ការអភិវឌ្ឍន៍មូលធនមនុស្ស (២) កសិពាណិជ្ជភាវូបនីយកម្ម និង (៣) ភស្តុភារ និងការសម្របសម្រួលពាណិជ្ជកម្ម (គមនាគមន៍)។ ការណែនាំរបស់ រដ្ឋាភិបាលសម្រាប់យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី រួមមាន (១) គម្រោងនីមួយៗគួរតែធំជាងមុនដែលនឹងនាំមកអត្ថប្រយោជន៍អភិវឌ្ឍន៍កាន់តែធំធេង និងមានប្រសិទ្ធផលកាន់តែខ្ពស់ (២) គម្រោងនីមួយៗគួរតែជាលទ្ធផលនៃការជ្រើសរើសដោយមត់ចត់ និងគួរមានទិសដៅច្បាស់លាស់ (៣) នៅពេលរៀបចំផែនការគម្រោងគួរផ្តោតលើទស្សនៈវិស័យវែងឆ្ងាយ និង (៤) នៅក្នុងដំណើរការរៀបចំគម្រោង គួរផ្តោតដោយហ្មត់ចត់ចំពោះអត្ថប្រយោជន៍អភិវឌ្ឍន៍ដែលគម្រោងនៃវិស័យនីមួយៗផ្តល់ឲ។

## ខ. យុទ្ធសាស្ត្រប្រចាំប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

14. យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស មានរយៈពេលស្របគ្នានឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ហើយក៏មានអាទិភាពស្របគ្នានឹងអាទិភាពរបស់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ផងដែរ។ យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសនេះក៏បានបញ្ចូលនូវអនុសាសន៍ពីរបាយការរបស់ IED និង អនុសាសន៍ត្រួសត្រាយក្នុងរបាយការត្រួតពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ីទៅលើយុទ្ធសាស្ត្រឆ្នាំ២០២០[9]ផងដែរ។

### ១. គោលបំណងនៃយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស

15. ស្របទៅនឹងអាទិភាពកំណែទម្រង់សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល គុណប្រយោជន៍អភិវឌ្ឍន៍នៃយុទ្ធសាស្ត្រ

---

[9] ធនាគារអភិវឌ្ឍន៍អាស៊ី ២០១៤។ *ការត្រួតពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិទៅលើយុទ្ធសាស្ត្រឆ្នាំ២០២០ ៖ ការឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់តំបន់អាស៊ី និង ប៉ាស៊ីហ្វិក ដែលកំពុងមានការផ្លាស់ប្តូរ*។ ទីក្រុងម៉ានីល។ សូមមើលផងដែរនូវឯកសាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០០៨។ *យុទ្ធសាស្ត្រឆ្នាំ២០២០ ៖ ការធ្វើការងារសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក ដែលគ្មានភាពក្រីក្រ*។ ទីក្រុងម៉ានីល។

ភាពជាដៃគូប្រចាំប្រទេស គឺការកាត់បន្ថយ ភាពក្រីក្រ និង ភាពងាយរងគ្រោះនៅកម្ពុជា។ ដើម្បីសម្រេចឲបាន នូវគោលបំណងនេះ យុទ្ធសាស្រ្តភាពជាដៃគូប្រចាំប្រទេស នឹងបញ្ចូលរបៀបវារៈយុទ្ធសាស្រ្តទាំងបីដែលមាន ក្នុងរបាយការការត្រួតពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិទៅលើយុទ្ធសាស្រ្តឆ្នាំ២០២០ ទៅក្នុងប្រតិបត្តិការទាំង អស់របស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅកម្ពុជា៖ (១) កំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នាតាមរយៈកំណើនសេដ្ឋកិច្ច ខ្ពស់ប្រកបដោយនិរន្តរភាព, និងការបង្កើត ពិពិធភាពកាលានុវត្តភាពសេដ្ឋកិច្ចឲបានកាន់តែច្រើន, ការទទួលបាន កាលានុវត្តភាពទាំងនេះកាន់តែទូលំទូលាយ, និង សំណាញ់សុវត្ថិភាពសង្គមដែលមានគោលដៅច្បាស់លាស់ដើម្បី ការពារជនក្រីក្រពុំរ៉ែ (២) កំណើនសេដ្ឋកិច្ចដែលមាន និរន្តរភាពផ្នែកបរិស្ថាន តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ដែលមិនប៉ះពាល់ដល់បរិស្ថាន និង អាកាសធាតុ, ការអនុវត្តន៍វិធានការការពារបរិស្ថាន, និងការពង្រឹងសមត្ថភាព ស្ថាប័ន និង (៣) កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់ តាមរយៈការសម្របសម្រួលគោលនយោបាយឲ បានកាន់តែជិតស្និទ្ធ ដើម្បីគាំទ្រដល់ប្រយោជន៍សាធារណៈក្នុងតំបន់ និងសកលលោក, និងការពង្រីកទីផ្សារតំបន់ សម្រាប់ទំនិញ សេវាកម្ម និងមូលធនឲកាន់តែមានវិសាលភាពកាន់តែធំជាងមុន។

16. ឆ្លើយតបទៅនឹងអនុសាសន៍នៃរបាយការនៃការត្រួតពិនិត្យឡើងវិញនៃពាក់កណ្តាលអាណត្តិទៅលើ យុទ្ធសាស្រ្តឆ្នាំ២០២០ យុទ្ធសាស្រ្តភាពជាដៃគូប្រចាំប្រទេស នឹងសង្កត់ធ្ងន់ទៅលើការពន្លឿនលំហូរធនធាន និង ការចែករំលែកចំណេះដឹង។ ភាពជាដៃគូរវាងវិស័យសារធារណៈ និងវិស័យឯកជន (PPPs), យុទ្ធសាស្រ្តដើម្បីស្វែង រកឲបានទូលំទូលាយនូវសហហិរញ្ញប្បទានពីដៃគូរអភិវឌ្ឍន៍នានា, និងចែករំលែកចំណេះដឹងដែលជាសកម្មភាព គន្លឹះរបស់យុទ្ធសាស្រ្តភាពជាដៃគូប្រចាំប្រទេសថ្មីនេះ។

## ២. សសរយុទ្ធសាស្រ្ត និងលទ្ធផល

17. យុទ្ធសាស្រ្តភាពជាដៃគូប្រចាំប្រទេសបានកំណត់យកសសរយុទ្ធសាស្រ្តចំនួនពីរ សម្រាប់សកម្មភាព របស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងប្រទេសកម្ពុជា ៖ (១) ការផ្សារភ្ជាប់ជនបទទៅនឹងតំបន់ទីក្រុង (២) ការអភិវឌ្ឍន៍ធន ធានមនុស្ស និងសង្គម។ សសរយុទ្ធសាស្រ្តសម្របសម្រួលមួយដែលបានកំណត់យក គឺការគ្រប់គ្រងវិស័យ សាធារណៈ។ សសរយុទ្ធសាស្រ្តទីមួយ ប្រើអភិក្រមសមាហរណកម្មមួយក្នុងសកម្មភាពអភិវឌ្ឍន៍ ដោយជ្រើសរើស យកតំបន់ដែលប្រជាជនក្រីក្រភាគច្រើនរស់នៅជាទិសដៅអភិវឌ្ឍន៍ ហើយផ្តោតយកចិត្តទុកដាក់ទៅលើការ- អភិវឌ្ឍន៍ច្រករបៀងដឹកជញ្ជូន និងច្រករបៀងសេដ្ឋកិច្ច ដើម្បីបើកផ្លូវឲខ្សែសង្វាក់ផលិតក្នុងស្រុកភ្ជាប់ជាមួយ ទីផ្សារតំបន់ និង ទីផ្សារពិភពលោក។ ក្នុងសសរយុទ្ធសាស្រ្តមួយនេះ ធនាគារអភិវឌ្ឍន៍អាស៊ី នឹងអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធភ្ជាប់ជនបទ ជាមួយទីក្រុង នឹងតំបន់(សកម្មភាពរួមមានការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្រ្តនិងការ គ្រប់គ្រងធនធានទឹក អគ្គិសនីនៅតំបន់ជនបទ ផ្លូវជនបទ ប្រព័ន្ធផ្គត់ផ្គង់ទឹកតាមតំបន់ជនបទ ហេដ្ឋារចនាសម្ព័ន្ធ ទីក្រុង ការថែទាំផ្លូវ និងការសម្របសម្រួលពាណិជ្ជកម្ម), ជ្រោមជ្រែងពាណិជ្ជភាវូបនិយកម្មតាមកសិដ្ឋាន និង លើកស្ទួយភាពប្រកួតប្រជែងនៃសហគ្រាសកសិធុរកិច្ច ដោយផ្តល់ឲពួកគាត់នូវហេដ្ឋារចនាសម្ព័ន្ធប្រសើរជាងមុន ដែលបើកផ្លូវឲទំនិញរបស់ពួកគាត់ទៅទីផ្សារតំបន់និងពិភពលោក។ សសរយុទ្ធសាស្រ្តអភិវឌ្ឍន៍ធនធានមនុស្ស និងសង្គម រួមមាន ការអប់រំកម្រិតមធ្យមសិក្សា ការអភិវឌ្ឍន៍ជំនាញ និង កិច្ចគាំពារសង្គម។ សកម្មភាពក្រោមការ គ្រប់គ្រងវិស័យសាធារណៈ រួមមាន កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ។ សសរយុទ្ធសាស្រ្តសម្របសម្រួលមួយនេះ នឹងកែលម្អអភិបាលកិច្ចតាមវិស័យ និងអភិបាលកិច្ច ក្នុងប្រទេស ព្រមទាំងជួយកាត់បន្ថយហានិភ័យផ្សេងៗនៅថ្នាក់គម្រោងផងដែរ។

18. **ជំរើសដោយហ្មត់ចត់ និងចំទិសដៅ ៖** យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស ជ្រើសរើសសកម្មភាពនិងទិសដៅអភិវឌ្ឍន៍នានារបស់ខ្លួនដោយហ្មត់ចត់និងល្អិតល្អន់។ យុទ្ធសាស្ត្រនេះ ផ្តោតសំខាន់លើវិស័យចំនួនប្រាំ (កសិកម្ម ធនធានធម្មជាតិ និងការអភិវឌ្ឍន៍ជនបទ, ទឹក និងហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មដទៃទៀតនៅតាមទីក្រុង, គមនាគមន៍, អប់រំ, និងហិរញ្ញវត្ថុ) និងវិស័យមួយដែលបញ្ច្រៀបចូលគ្រប់វិស័យទាំងប្រាំខាងលើគឺការគ្រប់គ្រងវិស័យសាធារណៈ។ សកម្មភាពនីមួយៗនៅក្នុងកម្មវិធីអភិវឌ្ឍន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅប្រទេសកម្ពុជាត្រូវបានឆ្លងកាត់ការត្រួតពិនិត្យនិងជ្រើសរើសយ៉ាងតឹងរឹង[10] និងត្រូវបានដាក់តាមអាទិភាព ដោយផ្អែកលើចំណុចដូចតទៅនេះ (១) ជាសកម្មភាពដែលនឹងដោះស្រាយរឺលុបបំបាត់ឧបសគ្គសំខាន់ណាមួយដែលរាំងស្ទះការអភិវឌ្ឍន៍នៅកម្ពុជា (២) ជាសកម្មភាពដែលស្របនឹងអាទិភាពរបស់រាជរដ្ឋាភិបាល (៣) ជាសកម្មភាពដែលស្របនឹងអនុសាសន៍ដែលចែងក្នុងរបាយការត្រួតពិនិត្យឡើងវិញនៃពាក់កណ្តាលអាណត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ីទៅលើយុទ្ធសាស្ត្រឆ្នាំ២០២០ (៤) ជាសកម្មភាពដែលនឹងផ្តល់លទ្ធផលគួរជាទីពេញចិត្ត និងផ្តល់គុណប្រយោជន៍អភិវឌ្ឍន៍ធំធេង (៥) ជាជាសកម្មភាពដែលគាំទ្រនិងបំពេញប្រយោជន៍បន្ថែមដល់សកម្មភាពអភិវឌ្ឍន៍នានារបស់ដៃគូអភិវឌ្ឍន៍ដទៃទៀត និង វិស័យឯកជន និង (៦) សមស្របទៅនឹងធនធានហិរញ្ញវត្ថុ និងធនធានមនុស្សរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

19. **សមាហរណកម្ម និងកិច្ចសហប្រតិបត្តិការដើម្បីបង្កើនប្រសិទ្ធភាពនិងគុណប្រយោជន៍អភិវឌ្ឍន៍ ៖** យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសមានគោលបំណងបង្កើនលទ្ធផលគម្រោងនិងកម្មវិធីឲអស់លទ្ធភាពតាមរយៈសមាហរណកម្ម និង កិច្ចសហប្រតិបត្តិការប្រពៃជាងមុនក្នុងចំណោមសកម្មភាទាំងឡាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការរៀបចំជ្រើសរើសកម្មវិធី និង គម្រោងនឹងផ្អែកលើលទ្ធផលអភិវឌ្ឍន៍ដែលរំពឹងទុក ជៀសជាងថាតើគួរតែផ្តោតតែក្នុងវិស័យណាមួយ។ ការរៀបចំនិងជ្រើសរើសបែបនេះ នឹងធ្វើឲសមាហរណកម្ម និង កិច្ចសហប្រតិបត្តិការរវាងគម្រោង និងកម្មវិធីនានានាំទៅដល់ការបង្កើនប្រសិទ្ធភាពនិងគុណប្រយោជន៍អភិវឌ្ឍន៍របស់គម្រោង និងកម្មវិធីទាំងនោះផងដែរ។ កិច្ចប្រជុំពិគ្រោះយោបល់ពេលរៀបចំកម្មវិធីប្រចាំប្រទេស ពេលត្រួតពិនិត្យឡើងវិញទៅលើប្រតិបត្តិការប្រចាំប្រទេស និងការរៀបចំគម្រោង និងកម្មវិធី ព្រមទាំង កិច្ចប្រជុំពិគ្រោះយោបល់នានារវាងសហការីតាមវិស័យនីមួយៗ និង ការតាមដានការអនុវត្តន៍គម្រោង ជាពេលដែលពិគ្រោះស្វែងរកឲឃើញថា កិច្ចសហប្រតិបត្តិការបែបណាដែលបង្កើនប្រសិទ្ធភាពនិងគុណប្រយោជន៍អភិវឌ្ឍន៍។

20. **ការតភ្ជាប់ទំនាក់ទំនងរវាងជនបទ ជាមួយនឹងទីក្រុង និងតំបន់ ៖**ខណៈពេលដែលកសិពាណិជ្ជភាវូបនីយកម្មជំនួសបន្តិចម្តងៗឲសកម្មភាពកសិកម្មដែលឲផលសម្រាប់តែផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃនោះ ការតភ្ជាប់ទំនាក់ទំនងរវាងតំបន់ជនបទ និងតំបន់ទីក្រុង នឹងផ្តល់នូវកាតាលីករមួយដែលបង្កើនប្រាក់ចំណូលរបស់ប្រជាជនរស់នៅតាមជនបទ និងទីក្រុងនានា។ ការតភ្ជាប់ទំនាក់ទំនងរវាងសហគមន៍នានាតាមជនបទនឹងទីក្រុងនានាដែលមានកំណើនសេដ្ឋកិច្ចនឹងបន្តរមានជាបន្តរបន្ទាប់ ហើយសហគមន៍ជនបទនឹងទទួលបានប្រយោជន៍ពីការមានទីផ្សារទំលំទូលាយជាងមុន ព្រមទាំងអាចទទួលបានសេវាសង្គមកាន់តែប្រសើរ។ នៅក្នុងបរិបទនេះ ការតភ្ជាប់ទំនាក់ទំនងរវាងតំបន់ជនបទ និងតំបន់ទីក្រុង តាមបណ្តោយច្រករបៀងសេដ្ឋកិច្ច មានសក្តានុពលក្នុងការរួមចំណែកគួរឱ្យកត់សម្គាល់ចំពោះកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា និង ការធ្វើសមាហរណកម្មប្រទេសកម្ពុជាទៅក្នុងទីផ្សារតំបន់។

---

[10] ដូចមានចងក្រងឯកសារនៅក្នុងការប៉ាន់ប្រមាណតាមវិស័យ (សង្ខេប) (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២)។

(១) **កសិពាណិជ្ជភាវូបនីយកម្ម ៖** យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសមានគោលបំណងលើកស្ទួយការផ្លាស់ប្តូរវិស័យកសិកម្មពីខ្សែសង្វាក់តម្លៃដែលមានមូលដ្ឋានផ្អែកលើការផ្គត់ផ្គង់ទៅជាខ្សែសង្វាក់តម្លៃដែលមានមូលដ្ឋានផ្អែកលើតម្រូវការទីផ្សារ។ អន្តរាគមន៍នានាក្រោមយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស នឹង (ក) ធ្វើឲវិស័យកសិកម្មផលិតផ្តោតលើតំរូវការទីផ្សារជាងមុន និងលើកកម្ពស់ការតភ្ជាប់ទំនាក់ទំនងទីផ្សារ (ខ) ធ្វើឱ្យការអនុវត្តន៍នៅតាមស្រែចម្ការកាន់តែមានប្រសិទ្ធផលខ្ពស់ តាមរយៈការប្រើប្រាស់ធនធានធម្មជាតិឲមានប្រសិទ្ធភាពល្អជាងមុន (ការប្រើប្រាស់ដី និង ទឹក) និង (គ) បង្កើនផលិតភាពតាមរយៈទិន្នផលដែលមានតម្លៃខ្ពស់ជាងមុន និងតាមរយៈឯកទេសកម្មប្រសើរជាងមុននៅក្នុងការដាំដុះស្រូវ និង កសិផលផ្សេងពីស្រូវដែលមានតម្លៃខ្ពស់។ ការធ្វើពាណិជ្ជកម្មទៅលើវិស័យកសិកម្ម នឹងទទួលបានកិច្ចគាំទ្របន្ថែមតាមរយៈការវិនិយោគបំពេញបន្ថែម ដូចមានរៀបរាប់លម្អិតខាងក្រោម និង ការអភិវឌ្ឍន៍វិស័យឯកជន។

(២) **ហេដ្ឋារចនាសម្ព័ន្ធជនបទ ៖** ការវិនិយោគទៅលើវិស័យសំខាន់ៗដែលរួមមាន គមនាគមន៍ថាមពលតាមជនបទ ទឹកនិងអនាម័យ និងប្រព័ន្ធធារាសាស្ត្រ នឹងផ្តល់នូវលទ្ធផលអភិវឌ្ឍន៍កាន់តែប្រសើរឡើងសម្រាប់កម្ពុជា។ ដើម្បីជម្រុញឲកំណើនសេដ្ឋកិច្ចកាន់តែខ្ពស់ បង្កើនផលិតភាព និងតភ្ជាប់ទំនាក់ទំនងទីផ្សារជនបទនិងទីក្រុង យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសនឹងផ្តោតយកចិត្តទុកដាក់ទៅលើ (ក) ការពង្រីកបណ្តាញផ្លូវខេត្ត និងជនបទ ដើម្បីលើកកម្ពស់ការតភ្ជាប់ទំនាក់ទំនង ពាណិជ្ជកម្ម និងទេសចរណ៍ ព្រមទាំងកាត់បន្ថយថ្លៃចំណាយលើការដឹកជញ្ជូនក្នុងស្រុកដែលសព្វថ្ងៃមានតម្លៃខ្ពស់ (ខ) ការកែលម្អសេវាផ្គត់ផ្គង់ទឹក និងអនាម័យដើម្បីជួយឲកម្ពុជាសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់ខ្លួន និង (គ) ការពង្រីកប្រព័ន្ធធារាសាស្ត្រ និងពង្រឹងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដើម្បីលើកកម្ពស់ផលិតភាពកសិកម្ម។

(៣) **ហេដ្ឋារចនាសម្ព័ន្ធតំបន់ទីក្រុង៖** ធនាគារអភិវឌ្ឍន៍អាស៊ីនឹងពង្រីកសេវាផ្គត់ផ្គង់ទឹក និងសេវាអនាម័យនៅតាមទីក្រុង (ក្រៅពីរាជធានីភ្នំពេញ) តាមបណ្តោយច្រករបៀងគមនាគមន៍អនុតំបន់នៅតាមក្រុងនានាដែលស្ថិតនៅតាមបណ្តោយព្រំដែន និង នៅតាមក្រុងនានាដែលមានកំណើនសេដ្ឋកិច្ចជុំវិញទន្លេសាប។ បន្ថែមពីលើការលើកកម្ពស់កិច្ចសហប្រតិបត្តិការ និង សមាហរណកម្មតំបន់ ការអភិវឌ្ឍន៍តាមទីក្រុងនឹងផ្តល់គុណប្រយោជន៍អភិវឌ្ឍន៍បន្ថែមដល់សកម្មភាពអភិវឌ្ឍន៍នានាតាមជនបទនិងទីក្រុង ដោយរាប់បញ្ចូលទាំងការអភិវឌ្ឍន៍ស្ថាប័ននិងការអភិវឌ្ឍន៍គោលនយោបាយផងដែរ។

(៤) **ការគ្រប់គ្រងធនធានធម្មជាតិ បំរែបំរួលអាកាសធាតុ និង ការកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយ៖** កំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នាអាចកើតឡើងបានអាស្រ័យទៅលើការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព រាប់បញ្ចូលទាំងទន្លេមេគង្គ និងបឹងទន្លេសាបផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងជួយដល់ (ក) ការកំណត់ផែនទីទៅលើ មុខងារប្រព័ន្ធអេកូឡូស៊ី និង ការប៉ាន់ប្រមាណទៅលើសេវាអេកូឡូស៊ី សម្រាប់ប្រើប្រាស់ជាទិន្នន័យនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដី (ខ) ការពង្រឹងស្ថាប័ន និងដំណើរការគ្រប់គ្រងធនធាន

ធម្មជាតិ និង (គ) ការកែលម្អទៅលើប្រព័ន្ធត្រួតពិនិត្យជីវចម្រុះ ដើម្បីរក្សាជីវចម្រុះនៃប្រព័ន្ធអេកូ-ឡូស៊ី។ យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស នឹង (ក) ដាក់បញ្ចូលបំរែបំរួលអាកាសធាតុទៅក្នុងការវិភាគតាមវិស័យ ការរៀបចំផែនការ និងការរៀបចំគម្រោង (ខ) សម្របសម្រួលនិងតភ្ជាប់ទំនាក់ទំនងឲកាន់បែប្រសើរឡើងរវាងកម្មវិធីបំរែបំរួលអាកាសធាតុ និងបរិស្ថានថ្នាក់ជាតិ និងថ្នាក់អនុតំបន់ និង (គ) ពង្រីកលទ្ធភាពទទួលហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការកាត់បន្ថយផលប៉ះពាល់ និងការបន្សាំទៅនឹងការបំរែបំរួលអាកាសធាតុ។ យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស នឹងលើកកម្ពស់សមាហរណកម្មរវាងបំរែបំរួលអាកាសធាតុ និង ការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ព្រមទាំងពង្រឹងផងដែរនូវការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្រិតថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ថ្នាក់ឃុំ និងថ្នាក់ភូមិ។

(៥) **កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់ និងការតភ្ជាប់ទំនាក់ទំនង** ៖ ការតភ្ជាប់ទំនាក់ទំនងនៅក្នុងប្រទេសរវាងតំបន់ជនបទ និងតំបន់ទីក្រុង ដែលមានភាពកាន់តែប្រសើរ នឹងធ្វើឲកម្ពុជាអាចទទួលយកប្រយោជន៍ពីការតភ្ជាប់ទំនាក់ទំនង និង សមាហរណកម្មតំបន់ដែលកំពុងកើតឡើងយ៉ាងរហ័ស ហើយព្រមពេលជាមួយនោះក៏ឲកម្ពុជាចូលរួមចំណែកក្នុងសកម្មភាពអភិវឌ្ឍន៍ថ្នាក់តំបន់ផងដែរ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រមហាអនុតំបន់ទន្លេមេគង្គ ឆ្នាំ២០១២-២០២០ ដែលត្រូវបានអនុម័តក្នុងខែ ធ្នូ ឆ្នាំ២០១១ សង្កត់ធ្ងន់ទៅលើគម្រោងដំណាក់កាលទី២ ដើម្បីធ្វើឲរបៀងសេដ្ឋកិច្ចតំបន់នៅក្នុងមហាអនុតំបន់ទន្លេមេគង្គកាន់តែមានភាពធំទូលាយ និង ជ្រាលជ្រៅ[11]។ នៅក្នុងប្រទេសកម្ពុជា គម្រោងដំណាក់កាលថ្មីនេះ មានមូលដ្ឋានផ្អែកលើអភិក្រមវិនិយោគពហុវិស័យដូចជាការអភិវឌ្ឍន៍តំបន់ទីក្រុង និង ការជម្រុញចលនាទំនិញ និងមនុស្ស តាមបណ្តោយរបៀងសេដ្ឋកិច្ច តាមរយៈ ការដឹកជញ្ជូន និងការសម្របសម្រួលពាណិជ្ជកម្ម វិធានការអនាម័យ និងភូតគាមអនាម័យ និង ភស្តុភារ ព្រមទាំងផ្អែកផងដែរលើគំហើញដែលទទួលបានពីការវិភាគទៅលើគំរោងអភិវឌ្ឍន៍នានាកំពុងអនុវត្តតាមរបៀងសេដ្ឋកិច្ច។ ដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមានបណ្តាលមកពីការតភ្ជាប់បណ្តាញដែលមានលក្ខណៈកាន់តែប្រសើរ យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស នឹងរួមចំណែកជាមួយកម្មវិធីមហាអនុតំបន់ទន្លេមេគង្គនានា ដោយ (ក) ពង្រឹងការអភិរក្សជីវចម្រុះ និង ភាពធន់មាំចំពោះការប្រែប្រួលអាកាសធាតុ ហើយស្របពេលជាមួយគ្នានោះ ត្រូវកាត់បន្ថយភាពរិចរិលនៃបរិស្ថាន និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (ខ) ដោះស្រាយកត្តារាំងស្ទះចំពោះកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា ដែលបណ្តាលមកពីបញ្ហាសុខភាពសាធារណៈតំបន់ និង បញ្ហាទេសន្តប្រវេសន៍ដើម្បីស្វែងរកការងារធ្វើ (គ) លើកកម្ពស់ការអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព ដែលផ្តល់ជាប្រយោជន៍សម្រាប់ទាំងអស់គ្នា ដោយសហប្រតិបត្តិការជាមួយវិស័យគមនាគមន៍ បរិស្ថាន ការអភិវឌ្ឍន៍ធនធានមនុស្ស និងការបង្កើតការងារ។

---

[11] ប្រទេសកម្ពុជានៅក្នុងមហាអនុតំបន់ទន្លេមេគង្គ (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២)។ ក្របខ័ណ្ឌវិនិយោគតំបន់របស់មហាអនុតំបន់ទន្លេមេគង្គ ឆ្នាំ២០១៣-២០២២ ក៏នឹងផ្តល់ការណែនាំសម្រាប់ការវិនិយោគនៅក្នុងកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់ផងដែរ។

21. **ការអភិវឌ្ឍន៍ធនធានមនុស្ស និងសង្គម ៖** ការវិនិយោគមិនគ្រប់គ្រាន់ទៅលើមូលធនមនុស្ស គឺជាកត្តាចម្បងមួយ ដែលនាំឲមានកង្វះខាតមូលធនមនុស្សក្នុងប្រទេសកម្ពុជា។

(១) **ការអភិវឌ្ឍន៍វិស័យអប់រំ ៖** ធនាគារអភិវឌ្ឍន៍អាស៊ីនឹងផ្តោតយកចិត្តទុកដាក់ទៅលើការអប់រំកម្រិតមធ្យមសិក្សា និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សំដៅសម្រេចឲបាននូវគោលដៅនានានៃផែនការយុទ្ធសាស្ត្រអប់រំរបស់រាជរដ្ឋាភិបាល ឆ្នាំ២០១៤-២០១៨។ ប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងវិស័យនេះ នឹងផ្តោតគោលដៅទៅលើការអប់រំកម្រិតមធ្យមសិក្សា (ថ្នាក់ទី៧-១២), ការពង្រីកលទ្ធភាពទទួលបានការអប់រំ, ការកាត់បន្ថយអត្រាបោះបង់ការសិក្សា ជាពិសេស នៅក្នុងចំណោមសិស្សក្រីក្រនិងកុមារីដែលរស់នៅតំបន់ដាច់ស្រយាល, កំណែលម្អកម្មវិធីសិក្សាឲពាក់ព័ន្ធនិងមានប្រយោជន៍ជាងមុន, និងការលើកកម្ពស់គុណភាពនៃការអប់រំ។

(២) **ការអភិវឌ្ឍន៍ជំនាញ៖** ប្រជាពលរដ្ឋវ័យក្មេងជាច្រើនក្នុងចំណោមប្រជាពលរដ្ឋវ័យក្មេងជាង ២០០.០០០នាក់ ដែលចូលរួមកម្លាំងការងាររៀងរាល់ឆ្នាំ មានជំនាញ និង ការអប់រំទាប។ កត្តានេះធ្វើឲផលិតភាព និង ភាពប្រកួតប្រជែងការងាររបស់ប្រទេសមានកំនត់។ យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស នឹងផ្តោតយកចិត្តទុកដាក់ទៅលើការជួយដល់រាជរដ្ឋាភិបាល ក្នុងការផ្លាស់ប្តូរពីកម្មវិធីអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រៅប្រព័ន្ធ ទៅជាការអប់រំ និងការបណ្តុះបណ្តាលក្នុងប្រព័ន្ធវិញ, លើកកំពស់គុណភាពនៃការអប់រំបណ្តុះបណ្តាលឲកាន់តែខ្ពស់, និងដាក់បញ្ចូលជំនាញបច្ចេកវិទ្យានៅកម្រិតក្រោយមធ្យមសិក្សាដែលឆ្លើយតបនឹងតម្រូវការ ទីផ្សារការងារ និងតំរូវការអភិវឌ្ឍន៍របស់ប្រទេស។ យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស ក៏នឹងផ្តោតយកចិត្តទុកដាក់ផងដែរ ទៅលើការលើកកំពស់ការចូលរួមចំណែកឲកាន់តែទូលំទូលាយពីវិស័យឯកជននៅក្នុងការបណ្តុះបណ្តាល និងការអប់រំវិជ្ជាជីវៈ។

(៣) **កិច្ចគាំពារសង្គម ៖** ដើម្បីគាំទ្រដល់គោលដៅអភិវឌ្ឍន៍ធនធានមនុស្ស និងសង្គម របស់រាជរដ្ឋាភិបាល និងការបង្កើតប្រព័ន្ធគាំពារសង្គមមួយ ដូចមានកំណត់ចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ប្រើប្រាស់បទពិសោធន៍កន្លងមក ហើយបន្តគាំទ្រដល់កិច្ចគាំពារសង្គម នៅក្នុងគម្រោងដែលកំពុងអនុវត្ត និងគម្រោងដែលគ្រោងអនុវត្ត ដូចជា ជំនួយឥតសំណងលើផ្នែកអនាម័យ ដែលផ្តោតគោលដៅទៅលើការកាត់បន្ថយភាពក្រីក្រ, គម្រោងសម្រាប់ជួយសម្រួលដល់ជីវភាពរស់នៅ (អាហារូបករណ៍ កម្មវិធីការងារសាធារណៈ និង កម្មវិធីបណ្តុះបណ្តាលជំនាញ), និង ការបន្តរៀនយកជំនាញសម្រាប់យុវជនបានបោះបង់ចោលការសិក្សា។

22. **ការគ្រប់គ្រងវិស័យសាធារណៈ ៖** រាជរដ្ឋាភិបាលកំពុងអនុវត្តកំណែទម្រង់ទូលំទូលាយលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង វិមជ្ឈការ និងវិសហមជ្ឈការ និងកំពុងពន្លឿនកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

(១) **វិមជ្ឈការ ៖** កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានគោលបំណងលើកកម្ពស់ការអភិវឌ្ឍន៍ប្រព័ន្ធ និងស្ថាប័ននៅថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ ព្រមទាំងសម្រេចឲបាននូវការ

អភិវឌ្ឍន៍សម្រាប់ទាំងអស់គ្នា តាមរយៈការផ្តល់សេវាតាមមូលដ្ឋានឲប្រសើរ។ បន្ថែមពីលើកិច្ចគាំទ្រដោយផ្ទាល់របស់ធនាគារអភិវឌ្ឍន៍អាស៊ីជុំវិញវិមជ្ឈការ និងវិសហមជ្ឈការ រួមមាន វិភាជន៍ការប្រគល់មុខងារទៅឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិ, វិមជ្ឈការសារពើពន្ធ, ការអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, និង ការបង្កើតយន្តការហិរញ្ញប្បទាននៅថ្នាក់ក្រោមជាតិ អន្តរាគមន៍តាមវិស័យនានារបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងត្រូវបានផ្តោតឲបានច្រើនបំផុតដូចដែលអាចធ្វើទៅបាន តាមរចនាសម្ព័ន្ធថ្មីៗនៃ វិមជ្ឈការ និងវិសហមជ្ឈការ[12]។

(២) **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៖** យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសនឹងបន្តគាំទ្រដល់ការកែលម្អលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្រសួងអភិវឌ្ឍន៍ជនបទ[13] និង ក្រសួងមួយចំនួនទៀត (ដែលត្រូវបានជ្រើសរើស) ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ពង្រឹងតម្លាភាព និង គណនេយ្យភាពនៃចំណាយសាធារណៈឲកាន់តែមានភាពប្រសើរឡើង។

សកម្មភាពនឹងផ្តោតយកចិត្តទុកដាក់ ទៅលើការកែលម្អ ការរៀបចំនិងការអនុវត្តន៍ថវិកា, គណនេយ្យ, ការគ្រប់គ្រងហិរញ្ញវត្ថុ, ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង, លទ្ធកម្ម, និងការត្រួតពិនិត្យ និងវាយតម្លៃ, ព្រមទាំងការពង្រឹងសវនកម្មខាងក្នុង និង ខាងក្រៅ ដែលរួមមានការគាំទ្រដល់អាជ្ញាធរសវនកម្មជាតិដែលកំពុងតែអនុវត្តន៍ក្នុងពេលបច្ចុប្បន្ន។

## ៣. កតាលិករ

23. **ការអភិវឌ្ឍន៍វិស័យឯកជន និងប្រតិបត្តិការវិស័យឯកជន ៖** យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស នឹងគាំទ្រដល់ការអភិវឌ្ឍន៍វិស័យឯកជនតាមរយៈការផ្លាស់ប្តូរវិស័យកសិកម្មពីកសិកម្មបែបយថាផលទៅជាកសិកម្មបែបពាណិជ្ជកម្ម, កែលម្អហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍, ពង្រឹងរបបនិយ័តកម្មដែលគ្របដណ្តប់ទៅលើស្ថាប័នហិរញ្ញវត្ថុនានា, ជម្រុញសហគ្រាសខ្នាតតូច និង លើកកម្ពស់ការចូលរួមរបស់វិស័យឯកជននៅក្នុងកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់។

(១) **កម្មវិធីវិស័យហិរញ្ញវត្ថុ ៖** ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងបញ្ចប់អនុកម្មវិធីទី៣ នៃកម្រងកម្ចីសម្រាប់កម្មវិធីវិស័យហិរញ្ញវត្ថុទី៣ ដែលមានប្រតិបត្តិការចាប់តាំងពីឆ្នាំ២០១១[14] ។ កម្មវិធីនេះគាំទ្រដល់ការអនុវត្តន៍ដំណាក់កាលបឋមនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ឆ្នាំ២០១១-២០២០ដែលទើបធ្វើបច្ចុប្បន្នភាព។ ក្រៅពីនេះទៀត ធនាគារអភិវឌ្ឍន៍អាស៊ី នឹងគាំទ្រធ្វើឲមានលទ្ធភាពប្រសើរជាងមុនក្នុងការទទួលបានប្រភពហិរញ្ញវត្ថុក្នុងប្រព័ន្ធ ជាពិសេសនៅតាមជនបទ ទាំងតាមរយៈការផ្តួចផ្តើមដែលពាក់ព័ន្ធនានារបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចជាការផ្តួចផ្តើមសម្រាប់គាំទ្រដល់ការរីកចម្រើនរបស់កសិដ្ឋានដែលមានលក្ខណៈជាពាណិជ្ជកម្ម និងសហគ្រាសតាមជនបទ និង តាមរយៈប្រតិបត្តិការដែលនាយកដ្ឋានប្រតិបត្តិការវិស័យឯកជន

---

[12] ការប៉ាន់ប្រមាណតាមវិស័យ (សង្ខេប) ៖ ការគ្រប់គ្រង់វិស័យសាធារណៈ (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២)។

[13] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម។

[14] ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១២។ *យុទ្ធសាស្ត្រអភិវឌ្ឍន៍ហិរញ្ញវត្ថុ ៖ ប្រទេសកម្ពុជា ឆ្នាំ២០១១-២០២០។* ទីក្រុងម៉ានីល។ ការប៉ាន់ប្រមាណតាមវិស័យ (សង្ខេប) ៖ ហិរញ្ញវត្ថុ (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២)។

របស់ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងអនុវត្ត រាប់បញ្ចូលទាំងការផ្តល់ហិរញ្ញទានពាណិជ្ជកម្ម និង ការលើកកម្ពស់លទ្ធភាពទទួលបានហិរញ្ញវត្ថុ សម្រាប់វិស័យឯកជនរយៈពេលវែង សម្រាប់សហ-គ្រាសខ្នាតតូច។

(២) **ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ៖** យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស នឹង អនុវត្តអភិក្រមកម្មវិធីគ្រប់ជ្រុងជ្រោយមួយដើម្បី (ក) លើកកម្ពស់ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌនិយ័តកម្ម និង ក្របខ័ណ្ឌស្ថាប័ន សម្រាប់ភាពជាដៃគូរវាងវិស័យ សាធារណៈ និង វិស័យឯកជន (ខ) អនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពភាពជាដៃគូរវាងវិស័យ សាធារណៈ និងវិស័យឯកជនមួយ នៅក្នុងរាល់បណ្តាក្រសួងពាក់ព័ន្ធ និងវិស័យឯកជនទាំងអស់ ដែលធ្វើការងារពាក់ពាន់នឹងភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន និង (គ) រៀបចំ កម្ចីសម្រាប់គម្រោងមួយ ដើម្បីជួយបង្កើតគម្រោងភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យ ឯកជនមួយដែលមានលក្ខណៈសមស្របមួយ។

(៣) **នាយកដ្ឋានប្រតិបត្តិការវិស័យឯកជន ៖** នាយកដ្ឋានប្រតិបត្តិការវិស័យឯកជនរបស់ធនាគារ អភិវឌ្ឍន៍អាស៊ី នឹងផ្តោតយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ រាប់បញ្ចូលទាំង ទ្រព្យកម្ចីឯកជន (private equity), គមនាគមន៍, កសិធុរកិច្ច, ការផ្គត់ផ្គង់ទឹក និងអនាម័យ, និង ការផ្តល់ហិរញ្ញប្បទានសម្រាប់ពាណិជ្ជកម្ម និង ខ្សែសង្វាក់ផ្គត់ផ្គង់ជូនដល់សហគ្រាសខ្នាតតូច និងមធ្យម។ ការវិនិយោគក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងការផ្តល់ជំនួយសម្រាប់វិស័យសាធា-រណៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងទទួលបានការគាំទ្រ ហើយជំនួយបច្ចេកទេស នឹងត្រូវបាន ពិចារណាដើម្បីសម្របសម្រួលដល់ការអភិវឌ្ឍន៍គម្រោង ការកាត់បន្ថយឧបសគ្គទីផ្សារ (entry barriers) ការកែលម្អអភិបាលកិច្ច និង ការអភិវឌ្ឍន៍សមត្ថភាព។

24. **អភិបាលកិច្ច និង ការអភិវឌ្ឍន៍សមត្ថភាព៖** ដើម្បីបំពេញបន្ថែមចំពោះកិច្ចគាំទ្រលើការគ្រប់គ្រងវិស័យ សាធារណៈពីលើមកក្រោមដែលធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស នឹងកាត់បន្ថយ ហានិភ័យផ្សេងៗ នៅក្នុងគ្រប់គម្រោងទាំងអស់ដែលទទួលបានមូលនិធិគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី។ ធនាគារ-អភិវឌ្ឍន៍អាស៊ី នឹងពង្រឹងការយល់ដឹងរបស់ខ្លួនអំពីបរិបទសេដ្ឋកិច្ចនយោបាយ ហើយពង្រឹងការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ និង សមត្ថភាពក្នុងការធ្វើលទ្ធកម្មតាមបណ្តាទីភ្នាក់ងារនានាដែលខ្លួនមានប្រតិបត្តិការជាមួយ ព្រមទាំងសម្របប្រតិបត្តិការរបស់ខ្លួនឲស្របតាមប្រព័ន្ធវិមជ្ឈការថ្មីៗ និង ផ្តល់កិច្ចគាំទ្រអភិវឌ្ឍន៍ស្ថាប័ននានាដែល ជាគោលដៅ។ វិធានការកាត់បន្ថយហានិភ័យនឹងត្រូវអនុវត្តលើគ្រប់គម្រោងទាំងអស់ដែលទទួលបានថវិកាគាំទ្រពី ធនាគារអភិវឌ្ឍន៍អាស៊ី ស្របតាមផែនការសកម្មភាពស្តីពីអភិបាលកិច្ច និងការប្រឆាំងអំពើពុករលួយទី២ (ឆ្នាំ ២០០៦) របស់ធនាគារអភិវឌ្ឍន៍អាស៊ី និង គោលការណ៍ណែនាំពីការអនុវត្តន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលបាន ពិនិត្យកែសម្រួលឡើងវិញ[15]។ យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស ក៏នឹងគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាព របស់មន្ត្រី លើផ្នែកលទ្ធកម្ម, ផ្នែកការគ្រប់គ្រងការអភិវឌ្ឍន៍ និង ភាពប្រែប្រួល, ព្រមទាំងភាពជាអ្នកដឹកនាំផងដែរ។

25. **សមធម៌ និងការបញ្ជ្រាបយេនឌ័រ ៖** អតុល្យភាពយេនឌ័រ គឺជាការព្រួយបារម្ភមួយនៅក្នុងប្រទេសកម្ពុជា ហើយ ធនាគារអភិវឌ្ឍន៍អាស៊ី ប្តេជ្ញាធ្វើការវិនិយោគទៅលើបញ្ហាសមធម៌យេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ដើម្បីនាំ

[15] ផែនការប៉ាន់ប្រមាណហានិភ័យ និងផែនការគ្រប់គ្រងហានិភ័យ (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២)។

ទៅដល់កំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នាដែលមានលក្ខណៈកាន់តែប្រសើរ។ ធនាគារអភិវឌ្ឍន៍អាស៊ី នឹងលើកកម្ពស់សមធម៌យេនឌ័រតាមរយៈលទ្ធផលនិងទិន្នផលដែលមានលក្ខណៈយេនឌ័រជាក់លាក់ ដែលផ្តល់នូវប្រយោជន៍ជាក់ស្តែងចំពោះស្ត្រីនៅក្នុងប្រតិបត្តិការរបស់ខ្លួន[16]។

26. **ការចែករំលែកចំណេះដឹង៖** ការត្រួតពិនិត្យឡើងវិញនៃពាក់កណ្តាលអាណត្តិទៅលើយុទ្ធសាស្ត្រឆ្នាំ២០២០ របស់ធនាគារអភិវឌ្ឍន៍អាស៊ី បានបង្ហាញឲឃើញថា ចំណេះដឹងជាកាតាលីករមួយសម្រាប់ជម្រុញដល់ការអភិវឌ្ឍន៍ និងបង្កើនគុណប្រយោជន៍នៃសកម្មភាពវិនិយោគរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ស្របតាមយុទ្ធសាស្ត្រចំណេះដឹងរបស់នាយកដ្ឋានអាស៊ីអាគ្នេយ៍នៃធនាគារអភិវឌ្ឍន៍អាស៊ី យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស មានយុទ្ធសាស្ត្រគ្រប់គ្រងចំណេះដឹង (Knowledge Management Strategy) មួយដែលស្របនឹងបរិបទប្រទេសកម្ពុជា ហើយនឹងត្រូវបានអនុវត្តតាមរយៈផែនការចំណេះដឹងដែលនឹងត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ យុទ្ធសាស្ត្រគ្រប់គ្រងចំណេះដឹងមានគោលបំណង (១) បង្កើត និង ផ្សព្វផ្សាយចំណេះដឹងនៅក្នុងវិស័យគោលដៅរបស់យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសឆ្នាំ២០១៤-២០១៨ ក្នុងលក្ខណៈជាផ្នែកមួយនៃវដ្តគម្រោង (២) ប្រើប្រាស់ឲបានកាន់តែប្រសើរនូវមាតិកាចំណេះដឹងនៃប្រតិបត្តិការនានា (៣) ទាញយកចំណេះដឹងពីស្ថាប័នជាតិ និងអន្តរជាតិ និង (៤) បង្កើនសមត្ថភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការផ្តល់ផលិតផលចំណេះដឹងក្នុងចំនួនណាមួយដែលបានឯកភាពគ្នាជារៀងរាល់ឆ្នាំ ហើយដែលស្របតាមតម្រូវការរបស់រាជរដ្ឋាភិបាល[17]។ ធនាគារអភិវឌ្ឍន៍អាស៊ី នឹងបន្តពង្រឹងការផ្សព្វផ្សាយចំណេះដឹងជូនអ្នកពាក់ព័ន្ធអំពីប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី តាមរយៈប្រព័ន្ធផ្សព្វផ្សាយអ៊ីនធឺណែត មជ្ឈមណ្ឌលព័ត៌មានសាធារណៈរួមគ្នាមួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនិងធនាគារពិភពលោក និងមជ្ឈមណ្ឌលធនធានសម្រាប់ការសិក្សារៀនសូត្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងប្រទេសកម្ពុជា[18]។

27. **ភាពជាដៃគូ៖** រាជរដ្ឋាភិបាលបានអនុម័តទៅលើយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូឆ្នាំ២០១៤-២០១៨ ដើម្បីកសាងភាពជាដៃគូគ្រប់ជ្រុងជ្រោយជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន។ យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស នឹងគាំទ្រឲមានការចូលរួមកាន់តែខ្លាំងក្លាពីធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងយន្តការ និង វេទិកាសម្របសម្រួលជំនួយអភិវឌ្ឍន៍។ ធនាគារអភិវឌ្ឍន៍អាស៊ី នឹងធ្វើការជ្រើសរើសវិស័យសម្រាប់ពង្រឹង ការតភ្ជាប់ទំនាក់ទំនងជាមួយ (១) ដៃគូអភិវឌ្ឍន៍[19] ដើម្បីធ្វើបង្កើនកិច្ចសហការ និងគៀងគរធនធានសហហិរញ្ញប្បទានឱ្យបានកាន់តែច្រើន (២) សង្គមស៊ីវិល[20] តាមរយៈការពិគ្រោះយោបល់ និងកិច្ចពិភាក្សាតុមូលកាន់តែញឹកញាប់ជាងមុន ដែលនឹងអនុញ្ញាតឲមានការពិភាក្សាដោយស្មោះត្រង់ និង កំណត់រកឱកាសពាក់ព័ន្ធ និង (៣) វិស័យឯកជន[21] ដើម្បីចូលរួមជាមួយសហគមន៍ធុរកិច្ចនៅក្នុងប្រតិបត្តិការវិស័យសាធារណៈ និងប្រតិបត្តិការវិស័យឯកជនរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

---

[16] ការវិភាគយេនឌ័រ (សង្ខេប) (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២ និង ផ្អែកលើលំហាត់មួយដែលសហការអនុវត្តជាមួយរដ្ឋាភិបាលដើម្បីធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រជាតិស្តីពីយេនឌ័រ)។

[17] យុទ្ធសាស្ត្រគ្រប់គ្រងចំណេះដឹង (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២)។

[18] យុទ្ធសាស្ត្រទំនាក់ទំនងប្រចាំប្រទេស (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២)។

[19]តារាងស្តីពីការសម្របសម្រួលការអភិវឌ្ឍន៍នៅក្នុងប្រទេស និង សូចនាករប្រតិបត្តិការ (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២)។

[20] ផែនការសហការជាមួយសង្គមស៊ីវិល (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២)។

[21] ការវាយតម្លៃវិស័យឯកជន (សង្ខេប) (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២)។

# ៣. ការអនុវត្តន៍យុទ្ធសាស្ត្រ

## ក. ធនធានធនធាន

28. **ធនធាន ៖** ចំណែកធនធានមូលនិធិអភិវឌ្ឍន៍អាស៊ីសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៣-២០១៤ មានចំនួន ២៧៤លានដុល្លារ នឹងត្រូវបានប្រើប្រាស់ដោយពេញលេញ។ គំរោងចំណែកថវិការយៈពេលពីឆ្នាំម្តងពីមូលនិធិអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៥-២០១៦ សម្រាប់ប្រទេសកម្ពុជា មានចំនួន ២៦០លានដុល្លារ ជាមួយនឹងថវិកាបន្ថែមចំនួន ៩៧,៩លានដុល្លារ ពីចំណែកមូលនិធិអភិវឌ្ឍន៍អាស៊ីថ្នាក់តំបន់។ ចំណែកធនធានមូលនិធិអភិវឌ្ឍន៍អាស៊ីសម្រាប់ប្រទេសកម្ពុជាចុងក្រោយ អាស្រ័យទៅលើលទ្ធភាពថវិកាដែលធនាគារអភិវឌ្ឍន៍អាស៊ីមាន និង លទ្ធផលនៃការវាយតំលៃប្រចាំឆ្នាំលើសមិទ្ធិកម្មប្រទេស ឆ្នាំ២០១៥ និង ឆ្នាំ២០១៦។ គំរោងចំណែកថវិការពីមូលនិធិអភិវឌ្ឍន៍អាស៊ីរបស់កម្ពុជាសម្រាប់ឆ្នាំ២០១៧ មានចំនួន ១៤៤លានដុល្លារ[22]។

29. **ការបែងចែកចំណាយ៖** ស្ថិតក្រោមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងធនាគារអភិវឌ្ឍន៍អាស៊ី កម្រិតអតិបរមានៃការចែករំលែកចំណាយរបស់ប្រទេសសម្រាប់កញ្ចប់វិនិយោគរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សំរាប់កម្ចី និងគម្រោងជំនួយបច្ចេកទេស នៅតែបន្តគ្មានការប្រែប្រួល។ គម្រោងនីមួយៗអាចទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ីរហូតដល់ ៩៥% នៃចំណាយសរុបរបស់គម្រោង[23]។ ការព្រមព្រៀងបែបនេះ ត្រូវបានរំពឹងថាអាចជួយសម្រួលដល់បញ្ហាកង្វះខាតផ្នែកហិរញ្ញវត្ថុ របស់សមភាគី។

30. **ធនធានបុគ្គលិក ៖** តម្រូវការបុគ្គលិកបម្រើការងារ រួមទាំងតម្រូវការបុគ្គលិករបស់និវាសដ្ឋានប្រចាំប្រទេស ប្រែប្រួលតាម សមាសធាតុនៃគម្រោងនិងកំរិតនៃការផ្ទេរការគ្រប់គ្រងគម្រោងទៅនិវាសដ្ឋានប្រចាំប្រទេស, តម្រូវការការងារផ្នែកចំណេះដឹង និងការផ្តោតយកចិត្តទុកដាក់ថ្មីៗរបស់យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស។ តម្រូវការបុគ្គលិកបម្រើការងារ នឹងត្រូវបានប៉ាន់ប្រមាណ និងកែសម្រួលក្នុងគោលបំណងធានាឲមានសមាសភាពមួយក្នុងកម្រិតសមស្របដើម្បីអនុវត្តយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស ប្រកបដោយប្រសិទ្ធភាព។

## ខ. និដ្ឋភាពទូទៅនៃកម្មវិធី

31. **ប្រតិបត្តិការទូទៅ ៖** កម្ចីសម្រាប់ឆ្នាំ២០១៥-២០១៧ ជាមធ្យមមានគម្រោងថ្នាក់ជាតិចំនួន៤-៥ គម្រោង និងគម្រោងថ្នាក់អនុតំបន់ចំនួន ១-២ គម្រោងក្នុងមួយឆ្នាំ ដែលគម្រោងនិមួយៗមានតម្លៃជាមធ្យមជាទឹកប្រាក់ចំនួន ៣២,៣លានដុល្លារ (កើនឡើងពីមធ្យមភាគ១៩,៤លានដុល្លារក្នុងមួយគម្រោងនៅក្នុងយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសឆ្នាំ២០១០-២០១២ និង មធ្យមភាគ២៥,៤លានដុល្លារក្នុងមួយគម្រោងនៅក្នុងយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស ឆ្នាំ២០១១-២០១៣)។ គម្រោងបម្រុងប្រចាំឆ្នាំមានគម្រោងថ្នាក់ជាតិចំនួនមួយ និង ថ្នាក់អនុតំបន់ចំនួនមួយ។ កម្មវិធីជាតិសម្រាប់ឆ្នាំ២០១៥-២០១៧ រួមមាន គម្រោងជំនួយបច្ចេកទេសចំនួន២២គម្រោង ក្នុងនោះ មាន៨ គម្រោងជាជំនួយបច្ចេកទេសរៀបចំគម្រោង, ៨ គម្រោងទៀតផ្តោតលើការអភិវឌ្ឍន៍សមត្ថភាព, ៤

---

[22] ផែនការប្រតិបត្តិការធុរកិច្ចប្រចាំប្រទេស (សេចក្តីព្រាង) ឆ្នាំ២០១៥-២០១៧ (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២)។

[23] ការចែករំលែកចំណាយប្រចាំប្រទេស និង ការផ្តល់ហិរញ្ញប្បទានសម្រាប់ចំណាយដែលសមស្រប (អាចរកមើលបានពីបញ្ជីរាយនាមឯកសារក្នុងឧបសម្ព័ន្ធ២)។

គម្រោងផ្ដោតលើគោលនយោបាយ និងការផ្ដល់ប្រឹក្សាយោបល់, និង ២ គម្រោងផ្ដោតលើការរៀបចំគម្រោងត្រៀមទុកជាមុន។ កម្មវិធីថ្នាក់តំបន់មានជំនួយបច្ចេកទេសសម្រាប់ការរៀបចំគម្រោងចំនួន២។

32. **ការកែលម្អគុណភាពគ្រប់គ្រងកញ្ចាប់ថវិការ ៖** ដើម្បីពង្រឹងគុណភាពគ្រប់គ្រងកញ្ចាប់ថវិការ យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស នឹង (១) បន្តពង្រឹងវិធានការទប់ស្កាត់ភាពមិនប្រក្រតី (fiduciary safeguards) (២) ជ្រើសរើសដោយហ្មត់ចត់ក្នុងការផ្ទេរការគ្រប់គ្រងគម្រោងមកឧនិវាសដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា (CARM) នៃធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីកែលម្អរដ្ឋបាលគម្រោងតាមរយៈកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធ និងកាន់តែខ្លាំងក្លាជាមួយអតិថិជន ដែលសមស្របនឹងសមត្ថភាពរបស់ CARM និងដោយមានការគាំទ្រពីស្នាក់ការធំ (៣) កែលម្អចំពោះការអនុវត្តន៍ឲបានខ្ជាប់ខ្ជួនទៅតាម "ភាពរួចរាល់គ្រប់សព្វ - readiness filters" និងការរៀបចំឲបានល្អជាមុនមុនពេលចាប់ផ្ដើមគម្រោង (៤) កសាងសមត្ថភាពគ្រប់គ្រងរបស់ទីភ្នាក់ងារប្រតិបត្តិ និងទីភ្នាក់ងារអនុវត្តជាពិសេស នៅក្នុងការធ្វើលទ្ធកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុ និង (៥) កែលម្អការត្រួតពិនិត្យ និងវាយតម្លៃតាមរយៈការលើកកម្ពស់ក្របខ័ណ្ឌលទ្ធផល និងបេសកកម្មត្រួតពិនិត្យរួមគ្នាសម្រាប់គម្រោងសហហិរញ្ញប្បទាន។

# ៤. ការគ្រប់គ្រងលទ្ធផល

## ក. ការត្រួតពិនិត្យ

33. ការអនុវត្តន៍យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសនឹងត្រូវបានត្រួតពិនិត្យឲបានកាន់តែជិតដល់ជាងនេះដោយ ប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលប្រចាំប្រទេស និងប្រចាំវិស័យដែលមានលក្ខណៈល្អប្រសើរជាងមុន ដែលនឹងត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំនៅពេលធ្វើការត្រួតពិនិត្យឡើងវិញទៅលើការគ្រប់គ្រងកញ្ចប់ថវិការប្រចាំប្រទេស និងពេលធ្វើបេសកកម្មរៀបចំកម្មវិធីប្រចាំប្រទេស (ឧបសម្ព័ន្ធ១)។ អ្នកឯកទេសដែលពាក់ព័ន្ធ នឹងធ្វើការវិភាគទៅលើលទ្ធផលតាមវិស័យ ដោយសហការជាមួយទីភ្នាក់ងារប្រតិបត្តិ និង ពង្រឹងសមត្ថភាពត្រួតពិនិត្យ និងវាយតម្លៃរបស់ទីភ្នាក់ងារប្រតិបត្តិ ក្នុងករណីចាំបាច់។

## ខ. ហានិភ័យ

34. **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងហានិភ័យនៃការធ្វើលទ្ធកម្ម និងការកាត់បន្ថយហានិភ័យ ៖** ដើម្បីកាត់បន្ថយហានិភ័យនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងហានិភ័យនៃការគ្រប់គ្រងផ្សេងៗ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងបន្តកិច្ចគាំទ្ររបស់ខ្លួន លើកម្មវិធីកំណែទម្រង់លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈការកែលម្អគណនេយ្យភាពហិរញ្ញវត្ថុរបស់ក្រសួងនានាដែលធ្វើការជុំវិញការងារអភិវឌ្ឍន៍ជនបទ និង ក្រសួងដែលត្រូវបានជ្រើសរើសដទៃទៀត ដែលធនាគារអភិវឌ្ឍន៍អាស៊ីធ្វើការជាមួយ និង លើកកម្ពស់សមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ វិធានការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីកាត់បន្ថយហានិភ័យក្នុងការធ្វើលទ្ធកម្ម និងហានិភ័យនៃអំពើពុករលួយនៅក្នុងប្រតិបត្តិការរបស់ខ្លួន រួមមាន (១) ការកំណត់រកអត្តសញ្ញាណហានិភ័យ និងការអនុវត្តន៍វិធានការកាត់បន្ថយហានិភ័យដែលកំណត់ចំគោលដៅដើម្បីធានាឲមានតម្លាភាព និងគណនេយ្យភាពតាមរយៈផែនការអភិបាលកិច្ច ផែនការប៉ាន់ប្រមាណហានិភ័យ និងផែនការគ្រប់គ្រងហានិភ័យ (២) ការរឹតបន្តឹង

ទៅលើលទ្ធកម្មគម្រោង និង ការអនុវត្តន៍វិធានការដើម្បីធានាឲមានប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃមួយដែលមានប្រសិទ្ធភាព (៣) ធ្វើការស៊ើបអង្កេតរួមគ្នាទៅលើភាពមិនប្រក្រតីនានានៅក្នុងគម្រោង ដែលទទួលបានហិរញ្ញវត្ថុគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី និង (៤) ការគាំទ្រឲមានការបន្តអភិវឌ្ឍន៍បន្ថែមទៅលើ*នីតិវិធីប្រតិបត្តិបទដ្ឋាន សៀវភៅណែនាំអំពីការងារលទ្ធកម្ម និង សៀវភៅណែនាំអំពីការគ្រប់គ្រងហិរញ្ញវត្ថុ* របស់រាជរដ្ឋាភិបាលដែលត្រូវបានធ្វើបច្ចុប្បន្នភាពសម្រាប់រាល់គម្រោង និងកម្មវិធីដែលទទួលបានជំនួយពីខាងក្រៅ នៅក្នុងប្រទេសកម្ពុជា និងការបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាល ក្នុងការអនុវត្តន៍គម្រោង និង កម្មវិធីទាំងនោះ ប្រកបដោយប្រសិទ្ធភាព។

# ក្របខ័ណ្ឌលទ្ធផលនៃយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស

| គោលដៅអភិវឌ្ឍន៍ប្រទេស |
|---|
| កសាងសង្គមមួយដែលមានសន្តិភាព ស្ថេរភាពនយោបាយ និងសន្តិសុខ តាមរយៈការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងសមធម៌។<br>១. កំណើន ៖ ធានាឲបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ ៧%។ កំណើននេះគួរមាននិរន្តរភាព ផ្តល់ប្រយោជន៍ចំពោះបុគ្គលគ្រប់រូប មានសមធម៌ និង មានភាពធន់នឹងវិបត្តិនានា។<br>២. ការងារ ៖ បង្កើតការងារឱ្យបានកាន់តែច្រើនសម្រាប់ប្រជាពលរដ្ឋ ជាពិសេសយុវជន តាមរយៈការធ្វើឱ្យមានភាពប្រសើរឡើងចំពោះភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីទាក់ទាញ និងលើកទឹកចិត្តការវិនិយោគក្នុងស្រុក និងពីបរទេស។<br>៣. សមធម៌ ៖ សម្រេចឱ្យបាននូវការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជា១% ក្នុងមួយឆ្នាំ ដ៏ដូចជាការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាដទៃទៀតផងដែរ។<br>៤. ប្រសិទ្ធភាព ៖ បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃសេវាសាធារណៈ សំដៅបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង។ |

| វិស័យដែលត្រូវបានជ្រើសរើសសម្រាប់គាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី | | | |
|---|---|---|---|
| គោលបំណងនៃវិស័យរបស់រាជរដ្ឋាភិបាល | លទ្ធផលតាមវិស័យដែលធនាគារអភិវឌ្ឍន៍អាស៊ីរួមចំណែក និងសូចនាករ | អន្តរាគមន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី | គំរោងធនធាន របស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅក្នុងអាទិភាពយុទ្ធសាស្ត្របន្ទាប់ |
| ១. វិស័យកសិកម្ម ធនធានធម្មជាតិ និងការអភិវឌ្ឍន៍ជនបទ (វិស័យស្នូលទី១ ៖ ហេដ្ឋារចនាសម្ព័ន្ធ និង វិស័យស្នូលទី២ ៖ បរិស្ថាន) | | | |
| កែលម្អផលិតភាព ពិពិធកម្ម និងការធ្វើកសិពាណិជ្ជភាវូបនីយកម្ម | ត្រឹមឆ្នាំ ២០១៨ ផលិតផលស្រូវមានការកើនឡើង រហូតដល់ ៩,៥លានតោន (ទិន្នន័យបឋមឆ្នាំ២០១៣ ៖ ៨,២លានតោន)<br>ត្រឹមឆ្នាំ២០១៨ ផលិតផលផ្លែឈើ និងបន្លែក្នុងស្រុក មានចំនួន ៥០% នៃការប្រើប្រាស់សរុបរបស់កម្ពុជា (ទិន្នន័យបឋមឆ្នាំ២០១៣ ៖ ៣០%)<br>ត្រឹមឆ្នាំ២០១៨ បង្កើនការងារកសិកម្មក្នុងប្រព័ន្ធ រហូតដល់ ១៥% (ទិន្នន័យបឋមឆ្នាំ២០១៣ ៖ ៩,៥%) ដែល ៣០% នៃការងារក្នុង ប្រព័ន្ធថ្មីៗ ដែលត្រូវបានបង្កើតឡើងជារៀងរាល់ឆ្នាំ គឺសម្រាប់ស្ត្រី | ការស្រាវជ្រាវលើវិស័យកសិកម្ម<br><br>សេវាផ្សព្វផ្សាយ និងសេវាផ្តល់ប្រឹក្សាយោបល់ជូនដល់កសិករ<br><br>ហេដ្ឋារចនាសម្ព័ន្ធក្រោយពេលប្រមូលផល និងការកែច្នៃកសិកម្ម<br><br>ហេដ្ឋារចនាសម្ព័ន្ធនិងការវិនិយោគទៅលើខ្សែសង្វាក់តម្លៃកសិផល<br><br>ការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ | ៨៥,៦ លានដុល្លារ សម្រាប់ ឆ្នាំ២០១៤-២០១៨ , ស្មើរនឹង ១០,៤% នៃកញ្ចប់ CPS និង ថវិកាបន្ថែមចំនួន ៣២,៤លានដុល្លារ ដែលជាថវិកាសហហិរញ្ញប្បទាន ក្នុងនោះ ៖<br><br>ESG: 76%<br><br>GEM: 100%<br><br>PSD: 59%<br><br>RCI: 24% |

| វិស័យដែលត្រូវបានជ្រើសរើសសម្រាប់គាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី | | | |
|---|---|---|---|
| គោលបំណងនៃវិស័យរបស់រាជរដ្ឋាភិបាល | លទ្ធផលតាមវិស័យដែលធនាគារអភិវឌ្ឍន៍អាស៊ីរួមចំណែក និងសូចនាករ | អន្តរាគមន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី | គំរោងធនធាន របស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅក្នុងអាទិភាពយុទ្ធសាស្ត្របន្ទាប់ |
| | (ទិន្នន័យបឋមឆ្នាំ២០១៣ ៖ ២០%) | | |
| **២. វិស័យអប់រំ (វិស័យស្នូលទី៥ ៖ ការអប់រំ)** | | | |
| បង្កើនកម្រិតនៃការបញ្ចប់ការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេស | អត្រាចុះឈ្មោះចូលរៀនរួមសម្រាប់ការអប់រំកម្រិតវិទ្យាល័យ គោលដៅ (SY2017/18): 45% (កុមារី 42%), ទិន្នន័យបឋម (SY2012/13): 27.4% (កុមារី 26.4%)<br>អត្រាបញ្ចប់ការអប់រំកម្រិតអនុវិទ្យាល័យ គោលដៅ (SY2017/18): 76% (កុមារី 76%), ទិន្នន័យបឋម(SY2012/13): 40.6% (កុមារី 40.3%)<br>ចំនួននៃការចុះឈ្មោះចូលរៀននៅក្នុងការបណ្តុះបណ្តាលក្នុងប្រព័ន្ធ គោលដៅ (SY2017/18): 17,600. ទិន្នន័យបឋម (SY2012/13): 8,700 | កំណែទម្រង់ប្រព័ន្ធ និង គោលនយោបាយ<br>ការស្តារ និងកសាងសាលារៀន<br>ការអភិវឌ្ឍន៍កម្មវិធីសិក្សា<br>ការផ្តល់ហិរញ្ញវត្ថុសម្រាប់វិស័យអប់រំ<br>ការបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ការបណ្តុះបណ្តាលបច្ចេកទេស | ៩០លានដុល្លារ សម្រាប់ឆ្នាំ២០១៤-២០១៨ , ស្មើរនឹង១០,៦% នៃកញ្ចប់ CPS និងថវិកាបន្ថែមចំនួន ១៥លានដុល្លារ ដែលជាថវិកាសហហិរញ្ញប្បទាន ក្នុងនោះ ៖<br>ESG: 33%<br>GEM: 100%<br>PSD: 33%<br>RCI: 0% |
| **៣. ការគ្រប់គ្រងវិស័យសាធារណៈ (កតាលិករ ៖ អភិបាលកិច្ច និងការអភិវឌ្ឍន៍សមត្ថភាព)** | | | |
| រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពលើកកម្ពស់ការអភិវឌ្ឍន៍ក្នុងមូលដ្ឋានប្រកបដោយនិរន្តរភាព និងកាត់បន្ថយភាពក្រីក្រ ភាពគួរឱ្យជឿជាក់ និងគណនេយ្យភាពថវិកាមានភាពប្រសើរឡើង។ | ត្រឹមឆ្នាំ២០១៨ យ៉ាងហោចណាស់នៅក្នុងក្រសួងចំនួន ៧ មានសូចនាករលទ្ធផលការអនុវត្តន៍ ដែលបង្ហាញពីទំនាក់ទំនងរវាងថវិកា និងគោលនយោបាយ និងកម្មវិធីតាមវិស័យ (ទិន្នន័យបឋមឆ្នាំ២០១៣ ៖ ២)<br>ត្រឹមឆ្នាំ២០១៧ ភាគរយនៃការចំណាយសាធារណៈ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ កើនឡើងរហូតដល់ ១០% នៃចំណាយសាធារណៈសរុប (ទិន្នន័យបឋមឆ្នាំ២០១៣ ៖ ៥,៧%) | វិមជ្ឈការ និងការផ្ទេរអំណាច<br>ការគ្រប់គ្រងចំណាយ និងហិរញ្ញវត្ថុសាធារណៈ<br>ការអភិវឌ្ឍន៍សមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាលមូលដ្ឋាន | ១៥៩,១លានដុល្លារ សម្រាប់ឆ្នាំ២០១៤-២០១៨ ស្មើរនឹង១៨,៧% នៃកញ្ចប់ CPS ក្នុងនោះ ៖<br>ESG: 19%<br>GEM: 81%<br>PSD: 40%<br>RCI: 0% |

| វិស័យដែលត្រូវបានជ្រើសរើសសម្រាប់គាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី | | | |
|---|---|---|---|
| គោលបំណងនៃវិស័យ របស់រាជរដ្ឋាភិបាល | លទ្ធផលតាមវិស័យដែល ធនាគារអភិវឌ្ឍន៍អាស៊ីរួមចំណែក និងសូចនាករ | អន្តរាគមន៍របស់ ធនាគារអភិវឌ្ឍន៍អាស៊ី | គំរោងធនធាន របស់ ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងអាទិភាព យុទ្ធសាស្ត្របន្ទាប់ |
| | ត្រឹមឆ្នាំ២០១៧ ការប្រមូលចំណូលពីពន្ធ និងមិនមានពន្ធ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ កើនឡើង ដល់១,៥% នៃផលិតផលក្នុងស្រុកសរុប (ទិន្នន័យបឋម ឆ្នាំ២០១២៖ ១%) | | |
| ៤. ការដឹកជញ្ជូន (វិស័យស្នូលទី១ ៖ ហេដ្ឋារចនាសម្ព័ន្ធ និង វិស័យស្នូលទី៣ ៖ កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់) | | | |
| ការធ្វើពាណិជ្ជកម្ម និង ការធ្វើចលនាទំនិញ និង សេវាកម្ម ត្រូវបានសម្របសម្រួល សមាហរណកម្មទីផ្សារក្នុងស្រុកទៅក្នុងតំបន់ និងពិភពលោក ត្រូវបានជម្រុញ | ត្រឹម ឆ្នាំ២០១៨ ការអនុញ្ញាតឱ្យធ្វើចរាចរណ៍តាមផ្លូវគោកឆ្លងកាត់ព្រំដែនប្រទេសវៀតណាម មានការកើនឡើងរហូតដល់ ៥០០ យានយន្ត (ទិន្នន័យបឋម ឆ្នាំ២០១៣ ៖ ៣០០)<br>ចរាចរណ៍ដឹកជញ្ជូនតាមរថភ្លើងមានការកើនឡើងរហូតដល់ ៦,៦០៩ លានតោនក្នុងមួយគីឡូម៉ែត្រ ក្នុងឆ្នាំ២០១៨ (ទិន្នន័យបឋម ឆ្នាំ២០១២ ៖ ៤,៩៣២លាន)<br>ត្រឹមឆ្នាំ២០១៨ អត្រាមរណភាពដោយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ត្រូវបានកាត់បន្ថយមកត្រឹម ៧ ក្នុង ១០.០០០យានយន្ត (ទិន្នន័យបឋម ឆ្នាំ២០១២ ៖ ១៣,៤) | ការកែលម្អផ្លូវខេត្ត និងផ្លូវជនបទ<br>ការគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវថ្នល់<br>ការស្តារផ្លូវរថភ្លើង<br>ការកែលម្អផ្លូវច្រករបៀងមហាអនុតំបន់ទន្លេមេគង្គ | ១៤៨លានដុល្លារ សម្រាប់ ឆ្នាំ២០១៤-២០១៨ , ស្មើរនឹង ១៧,៤% នៃកញ្ចប់ CPS និងថវិកាបន្ថែមចំនួន ១២៥,១លានដុល្លារ ដែលជាថវិកាសហហិរញ្ញប្បទាន ក្នុងនោះ ៖<br>ESG: 36.5%<br>GEM: 100%<br>PSD: 63.5%<br>RCI: 66.2% |
| ៥. ទឹក និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសេវាផ្សេងទៀតនៅតាមទីក្រុង (វិស័យស្នូលទី១ ៖ ហេដ្ឋារចនាសម្ព័ន្ធ , វិស័យស្នូលទី២ ៖ បរិស្ថាន និងវិស័យស្នូលទី៣៖ កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់) | | | |
| ត្រឹមឆ្នាំ២០២៥ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការផ្គត់ផ្គង់ទឹកមានសុវត្ថិភាព និង អនាម័យ | ត្រឹមឆ្នាំ២០១៨ ប្រជាពលរដ្ឋជនបទដែលទទួលបានទឹកមានសុវត្ថិភាពមានចំនួន ៦៧% និង ប្រជាពលរដ្ឋជនបទដែលទទួលអនាម័យ ដែលមានភាពប្រសើរ ជាងមុន ចំនួន ៦០% (ទិន្នន័យបឋម ឆ្នាំ២០១៣ ៖ | ការផ្គត់ផ្គង់ទឹក និង អនាម័យនៅតំបន់ជនបទ<br>ការផ្គត់ផ្គង់ទឹក និង អនាម័យនៅតំបន់ទីក្រុង | ១៨៣លានដុល្លារ សម្រាប់ ឆ្នាំ២០១៤-២០១៨ , ស្មើរនឹង ២១,៥% នៃកញ្ចប់ CPS និងថវិកាបន្ថែមចំនួន ២០លានដុល្លារ ដែលជា |

| វិស័យដែលត្រូវបានជ្រើសរើសសម្រាប់គាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី | | | |
|---|---|---|---|
| **គោលបំណងនៃវិស័យរបស់រាជរដ្ឋាភិបាល** | **លទ្ធផលតាមវិស័យដែលធនាគារអភិវឌ្ឍន៍អាស៊ីរួមចំណែក និងសូចនាករ** | **អន្តរាគមន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី** | **គំរោងធនធាន របស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងអាទិភាពយុទ្ធសាស្ត្របន្ទាប់** |
| | ៤៤,២% សម្រាប់ទឹក និង ៣៧,៥% សម្រាប់អនាម័យ)<br>ត្រឹមឆ្នាំ២០១៨ សមិទ្ធិកម្មទឹកនៅតំបន់ទីក្រុង មានភាពប្រសើរជាងមុន និងរាល់អ្នកផ្គត់ផ្គង់ទឹកសាធារណៈទាំង១២ មានស្វ័យភាព (ទិន្នន័យបឋមឆ្នាំ ២០១៣ ៖ ២)<br>ត្រឹមឆ្នាំ២០១៨ ទីក្រុងចំនួន២ដែលបានកែលម្អសេវារបស់ក្រុង នឹងមានប្រតិបត្តិការ ពេញលេញ និងការទទួលបានមក វិញនូវថ្លៃចំណាយលើការថែទាំ សម្រាប់សេវាសំខាន់ៗ (ទិន្នន័យបឋមឆ្នាំ២០១៤ ៖ 0) | ការកែលម្អបរិស្ថាននៅតំបន់ទីក្រុង | ចរិកាសហហិរញ្ញប្បទាន ក្នុងនោះ ៖<br>ESG: 89%<br>GEM: 100%<br>PSD: 20%<br>RCI: 20% |
| **៦. ហិរញ្ញវត្ថុ (វិស័យស្នូលទី ៤៖ ហិរញ្ញវត្ថុ)** | | | |
| ការប្រើប្រាស់សេវាហិរញ្ញវត្ថុដែលកាន់តែមានប្រសិទ្ធភាព និងមាននិរន្តរភាពពីសហគ្រាសវិស័យឯកជនមានការកើនឡើង | ត្រឹមឆ្នាំ២០១៨ គណនីកម្ចីមីក្រូហិរញ្ញវត្ថុដែលត្រូវបានបើក ឬចំនួនអ្នកខ្ចី ត្រូវបាន កើនឡើងរហូតដល់ ១.៨០០.០០០ ដោយបែងចែកទៅ តាមភេទ (ទិន្នន័យ បឋមឆ្នាំ២០១៣ ៖ ១.៥៥០.០០០ ក្នុងនោះស្ត្រីមានចំនួន ១.២៧២.០០០ នាក់ និង បុរសមាន ចំនួន ២៧៨.០០០នាក់)<br>ឥណទានវិស័យឯកជនសរុបពីធនាគារធៀបនឹងផលិតផលក្នុងស្រុកសរុប មានចំនួន ៦៥% ឬខ្ពស់ជាងនេះ ត្រឹមឆ្នាំ២០១៨ (ទិន្នន័យបឋម ឆ្នាំ២០១៣ ៖ ៤៧,៧%) | ការអភិវឌ្ឍន៍សម្ថភាពធនាគារជាតិ និង ប្រព័ន្ធទូទាត់ប្រាក់<br>គោលនយោបាយវិស័យហិរញ្ញវត្ថុ<br>ការទទួលបានហិរញ្ញវត្ថុ<br>ការអភិវឌ្ឍន៍វិស័យធានារ៉ាប់រង | ៣៥លានដុល្លារ សម្រាប់ឆ្នាំ២០១៤-២០១៨, ស្មើរ ៤,១% នៃកញ្ចប់ CPS ក្នុងនោះ ៖<br>ESG: 0%<br>GEM:57%<br>PSD: 57%<br>RCI: 0% |

CPS = យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស ESG = កំណើនសេដ្ឋកិច្ចដែលមាននិរន្តរភាពចំពោះបរិស្ថាន GEM= សមធម៌ និងការបញ្ជ្រាបយេនឌ័រ PSD = ការអភិវឌ្ឍន៍វិស័យឯកជន RCI = កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់ SY= ឆ្នាំសិក្សា

ប្រភព ៖ ធនាគារអភិវឌ្ឍន៍អាស៊ី។

# បញ្ជីរាយនាមឯកសារយោង

http://www.adb.org/Documents/CPS/?id=CAM-2014

១. ការវិភាគសេដ្ឋកិច្ច (សង្ខេប)
២. ការវិភាគភាពក្រីក្រ (សង្ខេប)
៣. ការវិភាគយេនឌ័រ (សង្ខេប)
៤. ការវាយតម្លៃបរិស្ថាន (សង្ខេប)
៥. ការវាយតម្លៃវិស័យឯកជន (សង្ខេប)
៦. ការវាយតម្លៃតាមវិស័យ (សង្ខេប) ៖ កសិកម្ម ធនធានធម្មជាតិ និង អភិវឌ្ឍន៍ជនបទ
៧. ការវាយតម្លៃតាមវិស័យ (សង្ខេប) ៖ ការអប់រំ
៨. ការវាយតម្លៃតាមវិស័យ (សង្ខេប) ៖ គមនាគមន៍
៩. ការវាយតម្លៃតាមវិស័យ (សង្ខេប) ៖ ទឹក និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសេវាដទៃទៀតនៅតំបន់ទីក្រុង
១០. ការវាយតម្លៃតាមវិស័យ (សង្ខេប) ៖ ការគ្រប់គ្រងវិស័យសាធារណៈ
១១. ការវាយតម្លៃហានិភ័យ និង ផែនការគ្រប់គ្រងហានិភ័យ (សង្ខេប)
១២. សូចនាករសម្រាប់ប្រទេស និង សូចនាករសម្រាប់កញ្ចប់ថវិការ
១៣. ការដាក់ពិន្ទុទៅលើការវាយតម្លៃសមិទ្ធិកម្មប្រចាំប្រទេស
១៤. ការរៀបចំបែងចែកចំណាយប្រចាំប្រទេស និង ការផ្តល់ហិរញ្ញប្បទាន សម្រាប់ចំណាយដែលសមស្រប
១៥. ការរៀបចំបង្កើតយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស
១៦. យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស ឆ្នាំ២០១១-២០១៣ ៖ ការវាយតម្លៃលើកចុងក្រោយ
១៧. ផែនការប្រតិបត្តិការធុរកិច្ចប្រចាំប្រទេស ឆ្នាំ២០១៥-២០១៧ (សេចក្តីព្រាង)
១៨. យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស ឆ្នាំ២០១១-២០១៣ ៖ ការផ្ទៀងផ្ទាត់ទៅលើការវាយតម្លៃលើកចុងក្រោយ

**ឯកសារបន្ថែម**

១៩. ការវាយតម្លៃតាមវិស័យ (សង្ខេប) ៖ ហិរញ្ញវត្ថុ
២០. កម្ពុជានៅក្នុងមហាអនុតំបន់ទន្លេមេគង្គ
២១. ផែនការសហការជាមួយសង្គមស៊ីវិល
២២. យុទ្ធសាស្ត្រទំនាក់ទំនងសាធារណៈប្រចាំប្រទេស
២៣. ការសិក្សាក្នុងប្រទេសកម្ពុជាទៅលើឧបសគ្គចំបងៗដែលរាំងស្ទះដល់ការអភិវឌ្ឍន៍ (ការគូសបញ្ជាក់អំពីចំណុចសំខាន់ៗ)
២៤. យុទ្ធសាស្ត្រគ្រប់គ្រងចំណេះដឹង